# អារម្ភកថា

*ការមិនដឹងគុណមាតាបិតា គឺជាកំហុសមួយដែលមិនអាចឲ្យនរណាជួយជំនួសបាន។ សង្ឃឹមថាកូនសៀវភៅនេះនិងជួយកែតម្រង់ទិសដៅ ដល់កូនប្រុសស្រីឲ្យមានការភ្ញាក់រលឹកបានផងនិងម្យ៉ាងទៀត នឹងបានជាអ្នកជំនួយដល់កូនទាំងឡាយគ្រប់ៗប្រាណឲ្យក្លាយទៅជាមនុស្សល្អផងដែរ។ ថ្វីត្បិតថាកូនសៀវភៅនេះវាមិនអាចផ្តល់តម្រូវការគឺ ចំណេះដឹងឲ្យបានគ្រប់គ្រាន់ក៏ដោយ តែវាក៏អាចជួយបានខ្វះៗដែរ បានសេចក្តីថាវាប្រសើរជាងអត់។ នាមយើងជាកូនរបស់ពុកម៉ែ យើងគួរតែស្រឡាញ់ពុកម៉ែឲ្យបានច្រើន មិនគួរស្រឡាញ់ជនដទៃជាងពុកម៉ែយើងឡើយ។ ពីព្រោះពុកម៉ែគឺជាអ្នកបង្កើតរូបរាងយើងគ្រប់ៗគ្នា មិនមែនជនខាងក្រៅផ្សេងពីពុកពីម៉ែនោះឡើយ។ ពុកលំបាកម៉ែគ្រាំគ្រាពុកវេទនាម៉ែស្ទើរក្ស័យ គឺព្រោះតែយើងជាកូននេះហើយ តើយើងចង់ឲ្យពួកគាត់រងក្តីវេទនាដល់ពេលណាទៀត។ការមិនសប្បាយចិត្តរបស់ពុកម៉ែ គឺនៅពេលដែលកូនគ្រប់ប្រាណមិនបានសេចក្តីសុខនេះឯង។ សូមឲ្យកូនគ្រប់គ្នាមានស្មារតីឡើងដើម្បីការពារ ថែរក្សាមាតាបិតារបស់យើងកុំឲ្យគាត់ទទួលភាពឈឺផ្សាទៀតអីណា។*

ការឈឺពើតផ្សាអួលណែនឱក ស្ទើរតែស្លាប់បាត់បង់ជីវិត វាមានច្រើនគ្រាណាស់មកហើយ ពុករួមជាមួយម៉ែបានសន្យាគ្នាជាស្រេចហើយថានិងស៊ូស្លាប់ដើម្បីកូនគ្រប់គ្នា។

ការសរសេរបែបនេះមិនមែនខ្ញុំចេះតែថានោះទេ ការពិតគឺវាបែបនេះមែន គ្មានមាតាបិតាណាដែលសុខចិត្តលះបង់ជីវិតកូនដើម្បីជីវិតខ្លួនឯងនោះទេ។ កូនកំព្រាគឺជារូបខ្ញុំនេះឯង ចំណែករូបអ្នកវិញ តើជាកូនកំព្រាដូចខ្ញុំដែរទេ? បើអ្នកមិនកំព្រាដូចខ្ញុំទេ ហើយអ្នកនៅមានមាតាបិតាដែលជាទឹកក់ក្ដៅសម្រាប់ខ្លួនរបស់អ្នក អ្នកគួរតែខិតខំថ្នាក់ថ្នមបមបីឲ្យបានល្អចំពោះពុកម៉ែរបស់អ្នក សូមកុំឆ្វេសប្រហេសឲ្យសោះ គោរពហើយគោរពទៀតគោរពឲ្យណាស់ គោរពកុំឲ្យចន្លោះអីណា។ សូមបុណ្យកុសលទាំងឡាយ កើតមានដល់កូនគ្រប់គ្នាសូមឲ្យកូនគ្រប់គ្នាបានក្លាយជាទាយាទនៃមនុស្សល្អ ជាកូនដែលមានការដឹងគុណមាតាបិតាជាដរាបតទៅ ម្យ៉ាងសូមឲ្យកូនប្រុសស្រីទាំងឡាយ ខំទំនុកបំរុងលើកសេចក្ដីល្អគ្រប់យ៉ាង ជូនដល់មាតាបិតារបស់អ្នកតែសូមកុំភ្លេចណាកុំភ្លេចធ្វើល្អឲ្យខ្លួនឯងផងណា ។

**ពីបំណាច់ល្អរបស់សាមណេរ ស៊ិន អក្ខរា**

**ព.ស.២៥៥៥**

# ១~ម៉ែឪឈឺព្រោះកូនៗ

✍📖

ពុកម៉ែ! កាលកូននៅតូចៗពុកម៉ែឈឺរួចម្តងទៅហើយឈឺព្រោះកូនៗ ឈឺកាលកូននៅក្រហមរងាលដេកលើកន្ទេលដែលម៉ែពុកក្រាលឱ្យកូនដេកនោះឯង។ ពុកម៉ែ! សម្បត្តិខ្ជោចផ្សាមានប៉ុណ្ណឹង នៅមិនគ្រប់គ្រាន់ចិត្តពុកម៉ែទៀត ដល់ពេលនេះកូនធំទៅហើយ នូវឡើយពុកម៉ែឈឺចាប់ម្តងទៀតឈឺព្រោះកូនរឹងមិនព្រមស្តាប់ មិនព្រមធ្វើតាមសម្តីរបស់ពុកម៉ែ។

កូនធ្វើកិរិយាមារយាទ មិនឱ្យពុកម៉ែរីករាយមិនឱ្យពុកម៉ែសប្បាយ តែកូនបែរជាមាន

ការតបស្នងចំពោះពុកម៉ែ ដោយឱ្យពុកម៉ែឈឺខ្លោចផ្សាក្នុងចិត្តហួសពីកាលដែលកូននៅកុមារភាពទៅទៀត។ កាលកូននៅតូច ពុកម៉ែប្រើឱ្យកូនធ្វើអ្វីកូនធ្វើតាម ហើយកូនសប្បាយក្នុងការងារនោះថែមទៀតផង កូនញញឹមញញែមរីករាយដោយភាពជាកូនកតញ្ញូរបស់ពុកម៉ែ។ ប៉ុន្តែឥឡូវការងារបន្តិចបន្តួច ម៉ែប្រើឱ្យកូនធ្វើកូនធ្វើមិនកើត កូនថារវល់ណាស់មិនអាចធ្វើបានទេ ម៉ែពុកសែនខ្លោចផ្សាណាស់ គ្រាន់តែប្រើកូនប៉ុណ្ណឹងកូនមិនធ្វើតាមពាក្យពុកម៉ែ។

ពុកម៉ែ! កូនខុសហើយតាមពិតការងារប៉ុណ្ណឹងកូនអាចធ្វើបានអាចជួយម៉ែពុកបាន តែកូនចង់ឈ្នះម៉ែពុក កូនមានបាបធ្ងន់ណាស់ណ៎ា

ម៉ែពុក ជាតិនេះព្រោះកូនមិនឱនលំទោនគោរព ប្រតិបត្តិលោក ជាម្ចាស់ជីវិតរបស់កូន ពុកម៉ែ! កូនសូមខមាទោស ណាំពុកម៉ែណាំ សូមពុកម៉ែ ឈប់កើតទុក្ខទៀតទៅណា។

## ២-ម៉ែឪឈឺព្រោះកូនៗ | ជាកំណាព្យ

✍📖

ម៉ែឪខ្លោចផ្សាឱរាសឹងប្រេះ

ព្រោះកូនមិនចេះត្រិះរិះតាមលោក

កូនរឹងទទឹងមិនដឹងឆ្លើយមក

ឪម៉ែទុក្ខសោកកើតរោគចិន្តា។

កាលកូននៅតូចឥតខ្វចមិនខ្ចិល

ម៉ែគ្មានមន្ទិលឥតប្រិលឡើយណា

ឪសែនរីករាយព្រោះតែកន្ទិដ្ឋា

កូនខ្ញុំឱស្សាហ៍នោះសែនរហ័ស។

ពេលនេះកូនរឹងមាំសមុំឆ្អឹងធំ

ភ្នែកមើលចំៗដូចស្អប់លោកណាស់

ឪម៉ែលោកប្រើប្រៀបអួសបព្រាស

លោកខ្មាសគេណាស់កូនតសម្តី។

ឈឺក្អួតធ្លាក់ឈាមព្រោះតែកល្យាណ

ទឹកភ្នែករហាមលើថ្ពាល់ទាំងពីរ

ទ្រូងនោះចុកណែនដូចជាផែនដី

សង្កត់ជីវីឱ្យសូន្យសង្ខារ។

ពុកម៉ែសង្ឃឹមថាបានរូបកូន

បានកូនមាសស្ងួនជាក្បូននារា

ចម្លងរូបលោកឱ្យផុតគ្រាំគ្រា

រួចក្តីវេទនាហើយបានសួស្តី។

ឥឡូវសង្ឃឹមបែរជាអាក់ខាន

ពឹងកូនមិនបានខុសអស់ហឫទ័យ

ត្អូញបានប៉ុណ្ណេះលែងពោលលែងស្ដី

លាកូនប្រុសស្រីទាំងគ្រាំឱរា។

## ៣~ម៉ែឪស្លាប់ព្រោះកូនៗ

✍📖

បើពោលពីម៉ែ! កាលដែលប្រសូតកូនមក ម៉ែស្ទើរតែស្លាប់ចោលកូនទៅហើយ ឯពុករបស់កូនវិញ លោកស្រវាប្រទីបដុតបំភ្លឺឱ្យម៉ែរបស់កូន ឬទៅតាមលោកគ្រូពេទ្យដើម្បីមើលកូនរបស់ពុក។ពុកម៉ែ! ស្ទើរតែមិនរស់ព្រោះកូនប្រសូតកូននៅពាក់កណ្ដាលអធ្រាត្រ លោកទាំងពីរមានការលំបាកឥតគណនាបានឡើយ ថ្វី

ត្បិតថាពុកមិនមែនជាអ្នកប្រសូតកូនក៏ដោយតែ ពុកបានរួមចំណែកមួយផងដែរដើម្បីកូន។

ភាពនៃការស្ទើរនឹងបាត់បង់ជីវិត របស់ម៉ែឪគ្រាកាលកូនប្រសូតម្តងរួចទៅហើយ តែឥឡូវនេះ ដល់ពេលកូនមានវ័យធំមានភាពជាបុរសស្ត្រី ហើយពុកម៉ែមិនមែនស្ទើរស្លាប់ទៀតទេ គឺលោកត្រូវមរណាដោយសារតែកូនក្បត់នឹងមាតាបិតា។ កូនប្រុសរបស់ពុកទៅញៀនថ្នាំម៉ាកូនស្រីរបស់មាតារត់តាមស្នេហា ធ្វើឱ្យម៉ែឪស្លាប់ទាំងរស់ស្លាប់ទាំងមិនទាន់បានឃើញកូនប្រុសស្រីរៀបកាផង។

ម៉ែឪត្រូវបាត់បង់ជីវិត ដោយសារតែកូនគ្រប់ៗប្រាណ ហេតុអ្វីកូនមិនយល់ពីបំណង

របស់លោក បែរជាធ្វើអ្វីស្រេចតែចិត្តរបស់ខ្លួនឯងយ៉ាងនេះ។ ពុកម៉ែ! ត្រូវស្លាប់ដោយសារតែកូនមិនជឿតាមឱវាទរបស់លោក លោកត្រូវទៅកាន់អបាយភូមិ ក៏ដោយសារកូនគ្រប់ប្រាណក្លាយជាប្រេតអត់ឃ្លាន ក៏ដោយសារកូនៗផងដែរ។

## ៤~ម៉ែឪស្លាប់ព្រោះកូនៗ ជាកំណាព្យ

✍📖

ម៉ែឪស្ទើរស្លាប់កាលពិសី
ប្រសូតចាកផ្ទៃនៃមាតា
ពុកក៏ហត់នឿយម្ដាយទុក្ខា
លោកទាំងទ្វេហាឈឺរួមគ្នា។

ទឹកភ្នែកស្រក់ហូរនៃម្តាយកូន
មិនរលាយសូន្យព្រោះសោភា
បិតាក៏ដែរណាពុំងា
ឈឺចាប់គ្រាំគ្រាព្រោះកល្យាណ។
ពុកម៉ែរួមស្លាប់ឥតស្តាយក្រោយ
ដើម្បីឆោមឆាយស៊ូក្ស័យប្រាណ
តើកូនដឹងទេពុកម៉ែបាន
លះបង់ហួសស្មានឱ្យដល់ថ្ងៃ។
ឱរ៉ាម៉ែឪត្រូវបាត់បង់
ព្រោះតែឆោមយង់មិនប្រណី
ខឹងនឹងរូបម៉ែព្រោះម៉ែស្តី
ម្តេចក៏ថ្លើមថ្លៃឥតពិចារណា។
កូនសម្លាប់ម៉ែប្រហារឪ

ឱ្យចុកពេកក្ងួវក្នុងឱរា
ស្លាប់ចិត្តស្លាប់កាយអស់សង្ខារ
ព្រោះតែបុត្រាបុត្រីហ្នឹង។
ពុកម៉ែស្លាប់ទៅតែពៅថ្ងៃ
រស់នៅធ្វើហីព្រោះចិត្តរឹង
កូនមិនសមពូជម្តេចព្រលឹង
រស់សែនរឹងត្អឹងនៅនឹងមុខ។

# ៥~បេះដូងម៉ែឪត្រូវជាំ

✍📖

កូនជាទីស្រលាញ់របស់ពុកម៉ែ កូនដឹងទេបេះដូងពុកម៉ែត្រូវរងនូវការឈឺផ្សាយ៉ាងក្រៃលែងបំផុត ក្នុងជីវិតរបស់ពុកម៉ែមិនដែលមានសេចក្ដីសុខដោយសារកូនណាមួយឡើយព្រោះកូនមិនយល់ពីដួងចិត្តរបស់ពុកម៉ែ។

កូនជាទីស្រលាញ់របស់ពុកម៉ែ ដោយសារកូននេះហើយ បានជាម៉ែត្រូវទទួលរងវិបត្តិខ្លោចផ្សា ឈានទៅរកសេចក្ដីស្លាប់យ៉ាងនេះណាកូនសំលាញ់ពុក។

កូនជាទីស្រលាញ់របស់ពុកម៉ែ!កូនកើត

មកធ្វើឱ្យម៉ែឪជាំបេះដូង ជាបំណែកទៅហើយ ព្រោះតែការបារម្ភរបស់ម៉ែឪ ទៅលើកូនប្រុសស្រីតែទោះបីជាបេះដូងរបស់ម៉ែឪ មានបេះដូងជាំយ៉ាងណាក៏ដោយ ការស្រលាញ់នឹងការថ្នមថ្នាក់ដែលមានចំពោះកូនគឺត្រូវតែមានជានិច្ច។

ម៉ែពុក!ជាទីស្រលាញ់ ម៉ែពុកមានព្រះគុណណាស់សម្រាប់កូនគុណលោកទាំងពីរគ្មានគុណណាប្រៀបបាននោះឡើយ កូនមិនល្អធ្វើឱ្យពុកម៉ែគ្រាំបេះដូង ហើយស្ទើរតែក្ស័យចាកចោលទ្វីបលោកថែមទៀតផង។

ម៉ែពុក! កូនសោកស្តាយដែលធ្វើឱ្យពុកម៉ែរងនូវការឈឺចាប់បែបនេះ ព្រោះតែកូនមិនល្អកូនអកតញ្ញូ ធ្វើឱ្យបេះដូងពុកម៉ែជាំ

ហើយស្ទើរបែកជាចំណែកៗទៀត។

ការធ្វើឱ្យពុកម៉ែ ចុកចាប់អួលណែនយ៉ាងនេះ គឺមិនមែនជាកាតព្វកិច្ចរបស់កូននោះទេ តែកូនសេពគប់មនុស្សមិនល្អ បានជាធ្វើឱ្យពុកម៉ែរងនូវសេចក្តីសោកសង្រេង គ្រប់ជំហាននៃការរស់នៅ។

## ៦-បេះដូងម៉ែឪត្រូវជាំ ជាកំណាព្យ

✍🕮

កូនអើយដឹងទេ កាលណោះមាសស្នេហ៍

យំសូមម៉ែបៅ ម៉ែហុចដោះឱ្យ

ឥតចាំយូរនៅ ឱ្យកូនធោមពៅ

ក្រេបយកឈាមម៉ែ។

ឯពុកកូនវិញ បេះដូងនោះមិញ

ច្រើនដោយការថៃ គុណលោកទាំងពីរ

លោកបានបង្វែរ ដើម្បីមាសស្នេហ៍

បានរស់នឹងគេ។

ចិត្តម៉ែឪជាំ នៅពេលកូនធំ

ចេះស្តីចេះដេរ កូនចេះតវ៉ា

យកឈ្មោះពុកមេ គ្រាំចិត្តច្រើនខែ

ព្រោះកូនកល្យាណ។

វិបត្តិដួងចិត្ត ព្រោះកូនមាសស្និទ្ធ

បាត់បង់សន្តាន កូនដើរផ្លូវខុស

លោកស្រណោះប្រាណ ថាកូនខ្ញុំបាន

រៀនថ្នាំលោកិយ៍។

## ៧~ស្នូរសម្រែកអ្នកម្ដាយ

✍...🕮

ឱ!កូនមាសម្ដាយអើយ កូនកុំប្រមាទណាកូនម៉ែ ម៉ែចង់ប្រាប់កូនថា ជីវិតរបស់ម៉ែ បើកូនគោរពប្រតិបត្តិកោតក្រែងជាមួយម៉ែ គឺម៉ែបានដល់នូវសេចក្ដីសុខឥតឧបមា ឬដូចជា

បានឡើងទៅកាន់ស្ថានសួគ៌ ទាំងនៅមានជីវិត ដូច្នោះឯង។ បើផ្ទុយពីកាគោរពទៅវិញនោះ ម៉ែមុខជានឹងក្សយសង្ខារមិនខាន តែម៉ែពោល មកដូច្នេះ មិនមែនចង់ឱ្យកូនប្រុសស្រីធ្វើយ៉ាង នេះដាក់រូបម៉ែនោះទេតែម៉ែចង់ឱ្យកូនបានក្លាយ ជាទាយាទនៃមនុស្សថ្លៃថ្នូរ។ កូនចាំទេ? ចាំស្នូរ សម្រែកម៉ែពេលដែលកូនប្រសូតមកទេសម្រែក របស់ម៉ែម្យ៉ាងចង់ឱ្យកូនម៉ែប្រសូតមកបានទទួល សិរីសួស្តីក្នុងជីវិតរបស់កូន ស្នូរសម្រែកមួយ ទៀតគឺម៉ែចង់ឱ្យកូនប្រុសស្រីម៉ែក្លាយជាមនុស្ស ដែលសង្គមគេត្រូវការគឺជាកូនល្អរបស់ម៉ែ ស្នូរ សម្រែកម៉ែមួយទៀត គឺជាស្នូរដែលម៉ែសូម អង្វរដល់មច្ចុរាជថា សូមមេត្តាកុំផ្តាច់ជីវិតខ្ញុំនឹង

កូនខ្ញុំអី ។

ម៉ែ!ពេលម៉ែនៅមានជីវិត កូននឹកមិនឃើញ មិនចងចាំសម្រែកស្រែកថ្ងូរដោយសាររូបកូនទេតែពេលម៉ែស្លាប់ទៅទើបកូនរលឹកដល់ស្នូរសម្រែករបស់ម៉ែ តែហួសពេលទៅហើយ កូនមិនអាចទាញពេលវេលា ឱ្យត្រឡប់ថយក្រោយបានឡើយឥឡូវនៅសល់តែឆ្អឹងដែលមិនចេះនិយាយមករកកូននោះទេ។

ម៉ែ! ស្នូរសម្រែករបស់ម៉ែជាគុណដែលបានញុំាងជីវិតកូនឱ្យរស់រហូតមកដល់សព្វថ្ងៃ។

## ៨~ស្នូរសម្រែកអ្នកម្ដាយ ជាកំណាព្យ

✍📖

កូនអើយម៉ែឈឺណាស់ចរណៃ

ឈឺស្មើរតែក្ស័យអស់សង្ខារ

ទឹកភ្នែកស្រក់ហូរលើភក្ត្រា

ព្រោះតែបុត្រានិងបុត្រី។

សម្រែកអ្នកម៉ែនេះណាពៅ

មិនសម្រាប់ឪកូនពិសី

តែសម្រាប់ម៉ែទោះយប់ថ្ងៃ

ស្រែកឃំឥតបីគ្មានស្រាកស្រាន្ត។

ស្នូរម៉ែមានន័យនោះច្រើនយ៉ាង

គ្មានអ្នកណាអាងជួសម៉ែបាន

មានតែម៉ែទេណាត្រើយត្រាណ
សម្រាប់កល្យាណចាកពីផ្ទៃ។
សួរមួយចំណែកគឺម៉ែចង់
ឱ្យបុត្រឆោមយង់មានសិរី
រុងរឿងចំរើនលើលោកិយ៍
សម្រាប់ចរណៃស្មើភ្នែកម្ដាយ។
សួរម៉ែមួយទៀតចាំណាមុំ
នោះគឺម៉ែសុំឱ្យឆោមឆាយ
មានឈ្មោះល្បាញល្បីឮខ្ចរខ្ចាយ
ទាំងជិតទាំងឆ្ងាយលើលោកា។
សួរម៉ែចុងក្រោយណាព្រលឹង
ម៉ែស្ដីដណ្ដឹងកុំឱ្យមរណា

អង្វរមច្ចុសូមមេត្តា

ខ្ញុំនិងបុត្តភ្ងាជួបគ្នារហូត។

## ៩~សម្រែកឪដណ្ដឹងចិត្តកូន

✍…🕮

មិនមែនមានតែម៉ែទេដែលកើតទុក្ខ ណាំកូនជាទីស្រលាញ់ ពុករបស់កូនក៏មានមួយចំណែកដែរ ក្នុងការទទួលរងនូវសេចក្ដីទុក្ខ ហើយនិងការឈឺចាប់ប្រចាំជីវិតណាកូនពុក។

ពេលម៉ែកូនដើរមិនរួច ពុកជាអ្នករាប់រងការងារទាំងឡាយទាំងពួង ពុកមានការតស៊ូទ្រាំលំបាកយ៉ាកយ៉ាប់ បេះដូងនេះត្រូវអូរអាប់

ចំណែកសេចក្ដីស្លាប់វិញ ក៏នៅរងចាំពុកផងដែរ តែពុកមិនខ្លាចពុកមិនញាប់ញ័រ ពុកមិនញញើត គឺពុកតស៊ូដើម្បីកូនប្រុសស្រីរបស់ពុក។

សេចក្ដីខាងលើនេះ ពុកលើកមកនេះ មិនមែនប្រណែននឹងម្ដាយ របស់កូននោះទេ ហើយក៏មិនមែនអួតនូវទង្វើរបស់ពុកដែរ។

កូនពុក! ពុកគ្រាន់តែចង់ដណ្ដឹងដល់ចិត្តកូនៗគ្រប់គ្នាថា (កូនកុំមើលកាលខ្លីគួរមើលកាលវែង) ចិត្តរបស់ពុកនូវតែល្អសម្រាប់កូនទោះបីពុកដេកលើកន្ទេល ងើបមិនរួចយ៉ាងណាក៏ដោយ ពុកនៅតែជួយកូនរហូត បណ្ដាំរបស់ពុកនូវតែលេចធ្លោ ចេញមកបង្ហាញពីដួងហឫទ័យរបស់ពុកថានៅតែល្អដដែលកូនអើយ!ពុកស្ដាយ

ណាស់ ព្រោះពុកមិនអាចនៅយាមនៅថ្នាក់ថ្នម រូបកូនរហូតបានទេ ពុកនឹងត្រូវលាចាកលោក ចោលកូនពុំខាន តែពុកនៅតែស្រលាញ់កូន។

បេះដូងរបស់ពុកគ្រាំគ្រាខ្លោចផ្សាទាំង ការឈឺចាប់ក៏កាន់តែរីកធំឡើង។កូនអើយ! ពុក មិនចង់ឃ្លាតពីរូបកូនឡើយ តែពុកមិនអាចត តាំងជាមួយនឹងមច្ចុបានទេណ៎ាកូនពុក ពុកលា កូនហើយ។

## ១០~សម្រែកឪដណ្ដឹងចិត្តកូន ជាកំណាព្យ

✍📖

ឪពុកនេះឯងណាឆោមមាសឆ្អិន

លោកប្រសប់ប៉ិនការងារទាំងឡាយ

ជួសរូបអ្នកម៉ែពេលដែលឈឺកាយ

ឪពុកខ្វល់ខ្វាយគ្រប់ពេលវេលា។

ម៉ែចង់ហូបអីម៉ែប្រាប់លោកពុក

បើម៉ែកើតទុក្ខឪពុកគ្រាំគ្រា

លោកពុករ៉ាប់រងឥតបីរួញរា

លោកតែងពុះពារគ្រប់គ្រាសម័យ។

តែពេលមួយនោះកូនស្រស់សោភា

ឱ្យលោកវេទនាក្នុងដួងហឫទ័យ

ព្រោះកូនប្រុសពុកផឹកស្រាមានស្រី

កូនស្រីមាសថ្លៃមានប្រុសសង្សារ។

លោកពុករស់នៅសែនខ្លោចផ្សាណាស់

រស់រងកម្មក្រាស់ពើតណែនចិន្តា

ពុកស្រក់ទឹកភ្នែកមកលើភក្ត្រា

ទទួលសោកាប្រចាំជីវិត។

ឱ!កូនមាសពុកម្តេចមិនអាសូរ

ដែលពុកខំថ្នូរទទូចសុំចិត្ត

សូមកូនស្តាប់ឪណា៎កូនមាសស្និទ្ធ

ពុកសែនវិបរិតដូចធ្លាក់នរក។

ពុកខំដណ្តឹងដង្ហោយហៅកូន

ស្តាប់ពុកណាស្ងួនកូនកុំសាងរោគ

តែកូនមិនស្តាប់និយាយតមក

ថាឥតយល់យោគដួងចិត្តកូនទេ។

# ១១~ជំនួញទឹកចិត្តម៉ែឪ

✍📖

ពុកម៉ែ! តែងតែជួញដូរវត្ថុសម្ភារៈគ្រប់បែបយ៉ាងដើម្បីកូន កូនបានហ៊ីហាស្លៀកពាក់ស័ក្តិសមនឹងគេ ចុះសំរុងនឹងគេគឺមកពីពុកម៉ែទាំងអស់ ម៉ែពុក! យកជីវិតដូរវត្ថុដែលទំនើបល្អៗសម្រាប់កូន តែពុកម៉ែមិនស្តាយជីវិតសោះឡើយ។

ជួញព្រឹកជួញថ្ងៃជួញល្ងាច ជួញយប់ព្រលប់ពាក់កណ្តាលអធ្រាត្រ ពីម៉ោងមួយទៅម៉ោងមួយ ពីថ្ងៃមួយទៅថ្ងៃមួយពីខែមួយទៅខែមួយ ពីឆ្នាំមួយទៅឆ្នាំមួយ ពុកម៉ែជួញដូរជា

និច្ចគ្មានពេលសម្រាកនោះទេ ពុកម៉ែខំដើម្បីកូន។ពុកម៉ែ! ខំហូរញើសបែកឈាមរងរបួសជួបគ្រោះថ្នាក់គ្រប់បែបយ៉ាង កាយលំបាកចិត្តសែនតោកយ៉ាក តែពុកម៉ែនៅញញឹមក្នុងការជួយកូនគ្មានពេលទំនេរនោះឡើយ។

ការលំបាកប្រចាំថ្ងៃប្រចាំខែប្រចាំឆ្នាំ សេចក្ដីលំបាកទាំងអស់នេះ ម៉ែពុកមិនមែនខំដើម្បីនរណាក្រៅពីកូននោះឡើយ ម៉ែពុកស៊ូលំបាកកាយចិត្តតែខ្លួនឯង តែម៉ែពុកមិនព្រមឱ្យកូនពុកម៉ែទទួលការលំបាកឡើយ។

ពុកម៉ែ! កាលពុកម៉ែខំជួញខំស្វះស្វែង ខំប្រឹងប្រែងខំខ្នះខ្នែងដើម្បីកូន តែពុកម៉ែមិនដែលរអ៊ូចំពោះបុត្រឬចំពោះកូនទេ ទាំងការ

ពពោះពីមួយខែរហូត៩ខែបួយ ទាំងម៉ែទាំងពុកដ៏ឧត្តម គឺឥតមានត្អូញត្អែរនោះទេ វាចាហាមករកកូន មានតែពាក្យពេជ្របង្គប់ដោយការអប់រំបន្ទំដល់កូន ដោយឧបនិស្ស័យដ៏ល្អត្រឹមត្រូវឱ្យបានក្លាយជាទាយាទ នៃមនុស្សខ្ពង់ខ្ពស់ណាំកូនសំលាញ់។

ពុកម៉ែ! ពេលដែលពុកម៉ែសុំរបស់អ្វីពីកូនវិញ មុននឹងកូនជូនពុកជូនម៉ែ កូនរអ៊ូរទាំដាក់ឱ្យពុកឱ្យម៉ែយ៉ាងនេះថា (ពុកម៉ែមិនចេះស្វែងរកដោយខ្លួនឯងទេ ឬដេកចាំតែសុំ ខ្ញុំគ្មានរបស់អ្វីឱ្យម៉ែពុកទេ) ពុកម៉ែ! ពេលកូនរអ៊ូហើយទើបកូនទិញឱ្យម៉ែពុកឱ្យបានបរិភោគ។

កូនរអ៊ូហើយ ទើបទិញជូនម៉ែពុកហើយ

កូនសួរបញ្ឈឺម៉ែពុកថា (ពុកម៉ែឆ្ងាញ់ទេ របស់ដែលបានពីការសុំគេ) ពុកម៉ែឆ្លើយយ៉ាងញញឹមបង្កប់ដោយភាពរំជើបរំជួលរអាក់រអួល ឆាបឆួលចេញពីដួងចិត្ត ដែលអាក់អន់ជាមួយនឹងពាក្យបញ្ឆៀចរបស់កូនថា (ម៉ែពុកឆ្ងាញ់! ឆ្ងាញ់ណាស់កូន) ហើយម៉ែពុកហូបនៅនឹងមុខកូនដើម្បីបញ្ជាក់ពីទឹកចិត្ត ដែលមានភក្តីភាពចំពោះកូនយ៉ាងស្មោះជាទីបំផុត។

ពុកម៉ែ!ទោះបីកូនបញ្ឈឺចិត្តពុកម៉ែយ៉ាងណាក៏ដោយ លោកពុកអ្នកម៉ែស៊ូទ្រាំនឹងការប្រមាថមើលងាយគ្រប់បែបយ៉ាង តែម៉ែពុកមិនអាក់អន់ចិត្ត តែបើម៉ែពុកអន់ចិត្ត ក៏ម៉ែពុកមិនឱ្យកូនដឹងដែរ ម៉ែពុកស៊ូលួចយំលួចសំរក់ទឹក

ភ្នែកតែងងនៅកន្លែងស្ងប់ស្ងាត់ ដោយការលាក់លៀម។

## ១២~ទំនួញម៉ែពុកពេលឃ្លាតកូន

ពុកម៉ែ! កាលដែលកូននៅតូចៗកូនដើរលេង ពុកឬម៉ែតែងតែតាមជួយការពារថែរក្សាកូនឥតបីទាស់ ពុកម៉ែ! ខ្លាចកូនតូចមានគ្រោះថ្នាក់ដោយសារឡានម៉ូតូបុកឬប៉ះពាល់កូន ធ្វើឱ្យកូនបាត់បង់ជីវិត ឃ្លាតពីរូបម៉ែព្រាត់ពីរូបពុក។កាលណោះបើរូបកូនមានបញ្ហា កូនឃ្លាតទៅឆ្ងាយ ពុកនឹងម៉ែតែងតែរួបរួមគ្នាជួយមើលជួយខ្នះខ្នែងដើម្បីកូន បើកូនស្លាប់ពុកម៉ែក៏ស្លាប់

ដែរ ម្ល៉ោះហើយបានជាពុកម៉ែខំគ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានរស់ជិត មិនឱ្យឃ្លាតពីទ្រូងម៉ែពីទ្រូងពុកនោះឡើយ។

កូនឃ្លាតតែមួយម៉ោង ពុកម៉ែព្រួយបារម្ភណាស់ខ្លាចកូនឃ្លាតទៅឆ្ងាយ បានជាពុកម៉ែខំស្រែកហៅរកកូន កូនម៉ែកូនពុកទៅណា ហើយឆាប់មករកម៉ែពុកណាំកូនម៉ែ។

សន្ទុះចិត្តរបស់ម៉ែពុក ទៅលើកូនប្រុសស្រីលឿនជាងផ្លេកបន្ទោរទៅទៀត ទោះបីកូនតូចរបស់ម៉ែរបស់ពុកទៅលេងកន្លែងណា ចិត្តដ៏បរិសុទ្ធចំពោះកូន គឺហោះឡើងទៅលើអាកាស ដើម្បីសំឡឹងមើលកូន។

បើកូនម៉ែពុកមិនអីពុកម៉ែរីករាយណាស់

តែកូនពុកម៉ែមានរឿងរ៉ាវវិញ ពុកម៉ែគឺរមែងព្រួយរន្ធត់មួយរំពេចឥតចាំយូរឡើយពុកម៉ែ! នេះកាលកូននៅតូចៗគឺពុកម៉ែព្រួយយ៉ាងនេះឯង។

ពុកម៉ែ! ពេលកូនធំឡើងដើរចេញពីផ្ទះទាំងការមិនបានប្រាប់ពុកម៉ែ តើពុកម៉ែមានការព្រួយបារម្ភយ៉ាងណា? ព្រួយម្យ៉ាងមិនបានឃើញកូនត្រឡប់មកផ្ទះវិញ ព្រួយម្យ៉ាងខ្លាចកូនមានរឿងជាមួយជនដទៃ។

ពាក់កណ្ដាលអធ្រាត្រ ពុកម៉ែអង្គុយចាំផ្លូវកូន ដូចកូនគោចាំមេរបស់វា មូសខាំផងស្រមោចខាំផងណាវរងាផង តែទោះបីជាយ៉ាងណាក៏ដោយទាំងកាយទាំងចិត្តគឺនៅតែរងទន្ទឹងចាំផ្លូវកូនរហូត។

ពុកម៉ែ! មានភាពក្រក្រីប្រចាំជីវិតក៏ដោយ ក៏ពុកម៉ែមិនចង់ឃ្លាតពីរូបកូនឡើយ ការវិនាសឬបាត់បង់ទ្រព្យសម្បត្តិដែលជាទីស្រលាញ់របស់ម៉ែឪ តែម៉ែឪពោលថាបាត់អ្វីក៏បាត់ទៅ តែពុកម៉ែមិនចង់ឃ្លាតពីកូនឡើយ ការព្រាត់កូនពីទ្រូង គឺស្មើនឹងការបាត់បង់ជីវិតរបស់ពុកម៉ែដែរ។សម្រាប់កូនវិញ ទោះបីកូនដឹងថាពុកម៉ែព្រួយបារម្ភនឹងកូនយ៉ាងណាក៏ដោយ សម្រាប់កូនវិញ ធ្វើមិនដឹងធ្វើមិនខ្វល់ពីលោកពុកពីអ្នកម៉ែដដែល កូនថែមទាំងមានការសេពគប់មិត្តភក្តិស្រីញីអូនបង បំផ្លាញទ្រព្យសម្បត្តិដែលជាញើសឈាម របស់ពុកម៉ែឱ្យហិនហោចអស់ទៀត។ ពុកម៉ែ!ទោះបីកូនធ្វើបែបនេះ ក៏ពុកម៉ែ

នូវតែខ្វល់នឹងកូនប្រុសស្រីដដែល រូបកូនត្រូវសង្គមស្អប់ខ្ពើម ត្រូវញាតិមិត្តជិតឆ្ងាយមិនរាប់រកក៏ដោយ ពុកម៉ែនៅតែទុកកូនស្មើនឹងកែវភ្នែកនឹងជីវិតរបស់ពុកម៉ែដដែល។

## ១៣~ចិត្តពុកម៉ែភ្លឺដូចថ្ងៃ

ពុកម៉ែ! កាលកូននៅតូចៗពុកម៉ែតែងតែជួយបំភ្លឺកូន ជួយនាំកូនឱ្យដើរផ្លូវត្រូវចង្អុលពីជីវិតពិតនៃការរស់នៅប្រចាំថ្ងៃ ពុកម៉ែ!បង្ហាត់កូនឱ្យឃើញសេចក្ដីល្អរបស់ជនដទៃ ឱ្យឃើញសេចក្ដីល្អរបស់ម៉ែរបស់ពុក។

ពុកម៉ែ! បង្ហាត់កូនឱ្យចេះស្រលាញ់គ្នា

រវាងបងប្អូនបង្ហាត់កូនឱ្យចេះពោលពាក្យពិរោះ ចំពោះបងប្អូនទៅវិញទៅមក បង្ហាត់កូនឱ្យចេះ គោរពគ្នាទៅវិញទៅមកផងដែរ។

ចិត្តពុកចិត្តម៉ែភ្លឺលើសដួងព្រះអាទិត្យ ព្រោះលោកបានបំភ្លឺរូបកូន តាំងពីចាប់កំណើត ក្នុងពោះម៉ែមកម្ល៉េះ រហូតរូបកូនបានធំធាត់ ឡើងមានវ័យដែលអាចហោះហើរខ្លួនឯងក៏ពុក ម៉ែនៅតែធ្វើជាដួងព្រះអាទិត្យ សម្រាប់បំភ្លឺឱ្យ ដល់កូនៗជានិច្ច។

ព្រះអាទិត្យមានពន្លឺភ្លឺចាំងចែងរស្មីស្សូរ្យ សែងបញ្ជាំងអស់ទ្វីបលោក យ៉ាងណាក៏ដោយ តែបើប្រៀបធៀបជាមួយនឹងចិត្តពុកម៉ែ នៅតែ ចិត្តពុកម៉ែមានពន្លឺភ្លឺជាងដដែល ព្រោះពុកម៉ែ

អាចបំភ្លឺបានទាំងថ្ងៃទាំងយប់ រីឯព្រះអាទិត្យវិញ បំភ្លឺបានតែពេលថ្ងៃតែប៉ុណ្ណោះ។

ពុកម៉ែ!កូនរស់នៅដូចមនុស្សខ្វាក់ភ្នែក ព្រោះមិនឃើញសេចក្ដីល្អរបស់ពុកម៉ែ ទាំងចិត្ត ដែលកូនធ្លាប់ទទួលបាននូវភាពភ្លឺស្វាងពីពុកម៉ែ ក៏រូបកូននេះមើលមិនឃើញ។

ពុកម៉ែ! រស់ដោយភាពជ្រាប់ត្រដូស ពិបាកជាងស្លាប់ទៅទៀត ក៏កូនមើលមិនឃើញ ពុកម៉ែអត់ឃ្លានគ្មានហូបយ៉ាងណាក៏ដោយ កូន កូនក៏នៅតែមើលមិនឃើញ។

ពុកម៉ែ!បានបំភ្លឺឱ្យកូនឃើញនូវអ្វីៗគ្រប់ យ៉ាង តែកូនបែរជាខ្វះសមត្ថភាព មិនអាចបំភ្លឺ អ្នកម៉ែលោកពុកមិនបាន ពុកម៉ែ! កូនឥតបាន

ការគ្រាន់តែពុកម៉ែក៏កូនគ្មានសមត្ថភាព ទំនុកបំរុងបានផង។ គំនិតរបស់កូនតាក់តែងដោយភាពល្ងិតល្ងង់លង់ក្នុងកិលេសនៃការល្មើសគុណពុកម៉ែ ចំណែករូបកូនវិញឃើញតែសេចក្តីអាក្រក់របស់ពុកម៉ែទេវិញ។ គំនិតជនពាលបានរុកទន្ទ្រានគ្រប់លើកូន ពុកម៉ែ! កូនមិនល្អកូនខ្វះសមត្ថភាព កូនខ្វះលទ្ធភាពក្នុងការជួយរូបម៉ែពុក ពុកម៉ែ!ស្រក់ទឹកភ្នែកលើផែនពសុធាជាមួយនឹងការគ្រាំគ្រាដួងចិត្ត កប់សៀតដោយក្តីវិយោគជាមួយក្តីទុក្ខ ព្រោះតែកូនមើលមិនឃើញសេចក្តីល្អរបស់ម៉ែពុក គុណរបស់ម៉ែពុកដូចជាលំហនៃវេហា។

ភាពតោកយ៉ាក និងការព្រួយបារម្ភ

របស់ម៉ែរបស់ពុក ដោយសារតែកូនមិនយល់ស្របតាមដួងចិត្តរបស់ម៉ែរបស់ពុក ថាភ្លើងហើយវាក្តៅ តែកូនដុតឱ្យពុកម៉ែក្តៅជាងភ្លើងទៅទៀត។

ពុកម៉ែ! ឆេះភ្លើងរលាកភ្លើងត្រឹមឈឺបានតែរូបរាងកាយតែប៉ុណ្ណោះ តែបើកូនដុតឱ្យពុកម៉ែក្តៅវិញ ពុកម៉ែត្រូវទៅកាន់នរកបានដោយសារកូននេះ។

ការឈឺចុកចាប់ ការស្រពាប់ស្រពោនបេះដូងរបស់ម៉ែឪ ព្រោះហេតុតែភាពអាម៉ាស់ដែលកូនធ្វើទៅលើរូបម៉ែនិងពុក ម្យ៉ាងកូនបានបង្កបញ្ហាក្នុងសង្គម ធ្វើឱ្យសង្គមមានភាពចលាចល។ ម៉ែ!ពុក! កូនអកតញ្ញូធ្វើឱ្យម៉ែធ្វើឱ្យពុក

ធ្លាក់ជ្រោះនៃក្តីវិបល្លាស ម៉ែ!ពុក! កូនសូមខមាទោសពីចំងាយ សូមម៉ែសូមពុកអភ័យទោសដល់កូនផងណាំម៉ែណាំពុក កូនគ្មានអ្វីជូនពុកជូនម៉ែឱ្យសមនោះទេ កូនមានតែម្រាមដៃទាំងដប់ លើកសំពះចំពោះពុកម៉ែ នឹងការថ្វាយបង្គំលោកពុកនឹកអ្នកម៉ែ ដែលជាទីស្រលាញ់ស្មើជីវិតរបស់កូន សូមម៉ែសូមពុកមេត្តាទទួលផងណាំម៉ែពុក។

ម៉ែយកហត្ថាទាំងពីរធ្វើជាអង្រឹង

របស់កូន ពុកម៉ែ!គ្រាដើមឡើយ កាលរូបកូននៅតូចៗ អ្នកម៉ែបីបមថ្នមកូនដោយហត្ថាទាំងពីរ ធ្វើជាអង្រឹងសម្រាប់កូនគ្រប់ៗគ្នាមិនមានពេលណាដែលម៉ែព្រមជាមួយពុកធ្វើដោយ

ការធ្វេសប្រហែសនោះទេ។

ទាំងពេលយប់ទាំងពេលថ្ងៃ ម៉ែ!ចំណាយទឹកដោះ ទាំងកម្លាំងកាយគឺហត្ថារបស់ម៉ែក្នុងការថែរក្សា កូនប្រុសស្រីយ៉ាងម៉ឺងម៉ាត់មានជំហររឹងមាំដោយការបមបីបុត្រ។

កាលកូននៅតូចយំពាក់កណ្ដាលអធ្រាត្រ ម៉ែចេញពីកន្លែងដេកព្រមដោយហត្ថាល្វត់ល្វន់មករកកូន ទាំងភាពរវើរវាយរាយមាយហើយម៉ែស្រវាឱបកូនយកកូនមកដាក់លើហត្ថាទាំងសងរបស់ម៉ែ។

ម៉ែ!លើកកូនចេញពីអង្រឹងមកដាក់លើអង្រឹងដៃម៉ែ រួចហើយម៉ែមើលក្នុងអង្រឹងក្រែងមានសត្វកាចខាំទិចកូន ម៉ែរលាស់អស់អង្រឹង

រលាស់ហើយរលាស់ទៀត ខ្លាចមិនអស់សត្វ ពេលរលាស់អស់ហើយ ទើបម៉ែបញ្ចេញវាចា បំពេកូនដែលកំពុងតែស្ថិតនៅលើហត្ថារបស់ម៉ែ បន្ទាប់មកទៀត ម៉ែឱ្យកូនបៅដោះដែលម៉ែខំសន្សំជារៀងរាល់ថ្ងៃទុកដើម្បីកូន។

ពេលកូនបៅដោះម៉ែ ម៉ែញញឹម ញញឹមដោយភាពស្រលាញ់ចំពោះកូន ឯកូនវិញមិនគិតពីការហត់នឿយរបស់ម៉ែឡើយ ឱ្យតែបានបៅដោះម៉ែ កូនលែងគិតអ្វីទាំងអស់ម៉ែសោកម៉ែគ្រាំឈឺផ្សាអស់ កំលាំងកាយក្នុងការបញ្ចេញកំលាំងយ៉ាងណា កូនមិនដឹងនោះទេ កូនបានបៅដោះ ហើយដេកលើដៃម៉ែទៀត ដេកលក់យ៉ាងស៊ប់។

# ១៤~ម៉ែបំពេកូន ជាកំណាព្យ

✍...📖

កូនអើយគេងទៅម៉ែនៅបំពេ

កុំយំមាសមេមាសស្នេហ៍ព្រលឹង

ម្ដាយឱ្យកូនគេងកន្លែងអង្រឹង

នៅពេលស្មើហ្នឹងព្រលឹងគេងណា។

កាលកូនស្នាក់នៅនៅក្នុងពោះម៉ែ

អ្នកម៉ែបំពេបំពេជីវ៉ា

ដៃម៉ែថ្នមៗថ្នមពៅកន្និដ្ឋា

ថ្នមបុត្រសង្សារសង្សារម៉ែថ្លៃ។

ឥឡូវកូនម៉ែប្រសូតមកហើយ

មានរូបឆោមឆាយកាយល្អឥតបី
កុំឃំណាំកូនព្រោះម៉ែចរណៃ

នៅជិតមាសថ្លៃហើយណាំសោភា។

ម៉ែយោលអង្រឹងនិងមើលមុខកូន

ខ្លាចកូនមាសស្ងួនត្រជាក់រងា

ឱ!កូនមាសឆ្អិនកូនមិនកំព្រា

រូបកូនពិតជាបាននូវសួស្តី។

បើកូនឃ្លានបៅកូនស្រែកប្រាប់ម៉ែ

ព្រោះដោះអ្នកម៉ែនៅក្បែរពិសី

ម៉ែឱ្យកូនបៅម៉ែមិនគិតថ្លៃ

កូនកុំព្រួយអីណ៎ាពៅពន្លក។

ឃើញទេនេះដោះរបស់អ្នកម៉ែ

ដូចនេះសូមស្នេហ៍ឆាប់គេងណ៎ាកូន

ភ្ញាក់ឡើងពេលណាបៅដោះម៉ែផ្ទួនៗ

ឆាប់ធ្វើឱ្យខ្លួនកូនម៉ែឆាប់ធំ។

# ១៥~ចិត្តម៉ែស្រទន់ដូចមេឃស្រទុំ

✍...📖

ម៉ែ! ម៉ែតែងឱ្យអភ័យកូនជានិច្ច គ្រប់ពេលវេលានៃការរស់នៅ ម៉ែតែងតែផ្តល់ភាពកក់ក្តៅឱ្យដល់រូបកូន សេចក្តីស្នេហារបស់ម៉ែមកលើរូបកូន គឺមានទំហំធំណាស់ ក្រៃក្រាស់ជាងធរណីល្វឹងល្វើយដូចវេហា។

ម៉ែ! ចិត្តម៉ែស្រលាញ់កូនមានភាពស្រទន់ដូចមេឃស្រទុំ មកលើរូបកូនគ្រប់ៗគ្នាធ្វើឱ្យកូនមានសិរីសួស្តី មានភាពខ្ពង់ខ្ពស់រីករាលដាល សមប្រកបដោយការជោគជ័យគ្រប់ពេលវេលា។សម្រាប់ឥរិយាបថ៤របស់ម៉ែ មានតែ

ភាពទន់ទោរមករករូបកូន ក្ដីមេត្តាទាំងការអាសូរ ការឱ្យអភ័យប្រណីដល់រូបកូន ការសណ្ដោងសណ្ដូងដល់រូបកូនឱ្យផុតពីជ្រោះកាច គឺអំពើពុករលួយ ប្រចាំជីវិតប្រចាំលោកិយ៍ផងដែរ។

ម៉ែ! ទឹកចិត្តរបស់ម៉ែប្រៀបបីដូចជាទឹកអម្រឹតដែលស័ក្តិសិទ្ធិអស្ចារ្យ ក្នុងលោករកវត្ថុណាមួយប្រៀបផ្ទឹមពុំបានឡើយ ទាំងមាសទាំងពេជ្រទាំងប្រាក់ នឹងវត្ថុដ៏ទៃក្រៅពីនេះក៏យកមកប្រៀបផ្ទឹម នឹងទឹកចិត្តម៉ែមិនបានឡើយ។ ម៉ែ! ម៉ែឱបក្រសោបកូនដោយភាពកក់ក្ដៅស្នេហ៍គ្រស្នោះនឹងកូនជាទីបំផុត ម៉ែ!ភ្នែកទាំងគូរជាទីស្រលាញ់របស់ម៉ែ តែម៉ែថាមិនស្មើនឹង

កូនរបស់ម៉ែទេ ហើយម៉ែនឹកភ្នកក្នុងចិត្តថែមទៀតថា បើវិប្បដិសារីកើតមានដល់កូន ម៉ែ!ម៉ែនឹងព្យាយាម ដណ្ដើមយកវិប្បដិសារីពីកូនឱ្យបាន។ ម៉ែ! ម៉ែជាទីស្រលាញ់របស់កូន ម៉ែមិនដែលមានទោមនស្សចំពោះកូន ដោយសារទង្វើរបស់កូនទេ ទោះបីកូនមានសោកនាដកម្មប៉ុណ្ណា ម៉ែតែងតែមានសេចក្ដីអនុគ្រោះឱ្យដល់កូនជានិច្ច ម៉ែ!ម៉ែថែមទាំងលួងលោមកូនទៀតថាកូន!កូន!កុំព្រួយណ៎ាកូនម៉ែ ដរាបណាមានម៉ែកូនរបស់ម៉ែគឺគ្មានបញ្ហានោះទេ។

ម៉ែ! ការសោកសល់វិយោគគ្រាំគ្រារងាឱរាទាំងការឈឺផ្សា ចិន្ដាពោរពេញទៅដោយយោបំផ្សំជាមួយនឹងក្ដីវិបល្លាស លាយដោយក្ដី

អាម៉ាស់ បញ្ច្រាស់លាយឡំដោយសុខនឹងទុក្ខ យ៉ាងណាក៏ដោយ ម៉ែ!ម៉ែនូវតែមានទឹកមុខ បង្កប់ដោយក្ដីអាណិតចំពោះកូន ម៉ែ!ទាំងនេះគឺជាសេចក្ដីពិតដែលស្ថិតនៅក្នុងចិត្តរបស់ម៉ែ។

ម៉ែ!ម៉ែពូកែណាស់ម៉ែចេះកែច្នៃនូវរឿងរ៉ាវគ្រប់យ៉ាង រឿងតូចតាចម៉ែធ្វើឱ្យអស់ទៅ រឿងធំម៉ែខំកែច្នៃរឿងនោះឱ្យកាន់តែតូច ម៉ែ! ម៉ែលើកកូនឱ្យផុតពីរឿងអំពល់ គ្រប់បែបយ៉ាងទាំអស់។ ម៉ែ!ម៉ែមិនអស់ចិត្ត កាលណាបើម៉ែជួយកូនមិនបាន ព្រោះធ្លាប់ជួយកូនតាំងពីកូនពូនសម្ងំនៅក្នុងផ្ទៃម៉ែ!ម៉ែជួយកូនបានទាំងអស់ ។ដូច្នេះ ម៉ែ!ចិត្តម៉ែនៅតែមានភាពស្រទន់មកលើរូបកូន មិនចេះឆ្អែតមិនចេះជិនឆ្អន់នៅក្នុង

បេះដូងរបស់អ្នកម៉ែ។

## ១៦~ម៉ែធ្វើពលីកម្មដើម្បីកូន

✍...📖

ម៉ែ!ពេលកូនប្រសូត្រមកហើយ ម៉ែ!ម៉ែពលីកម្មគ្រប់យ៉ាងដើម្បីកូន ម៉ែ! ម៉ែធ្វើពលីកម្មទាំងផ្លូវកាយពលីកម្មទាំងផ្លូវចិត្ត ហើយអ្វីដែលម៉ែធ្វើពលីកម្មច្រើនជាងគេគឺកំលាំងចិត្តម៉ែ!ចិត្តរបស់ម៉ែសែនហត់នឿយណាស់ សម្រាប់ការធ្វើពលីកម្ម។ ផែនដីដែលពលីកម្មយ៉ាងធំធេងក្នុងការទំនុកបំរុង ទ្រអស់មហាជនរាប់សែនលានកោដិ ទោះជាសាស្ត្រាវុធដូចជាចបកាប់

មកគាស់រំលើង ឬមនុស្សធ្វើផ្ទះទំហំធំដូចជាផ្ទះវិទ្យារាប់រយជាន់ឬមនុស្សបន្ទោបង់មូត្រលាមកយ៉ាងណាក៏ដោយ ក៏ផែនដីអាចពលីកម្មដល់មនុស្សទាំងអស់បាន។

ម៉ែ! ចំណែកម៉ែវិញធ្វើពលីកម្មលើសផែនដីទៅទៀត។

ម្យ៉ាងម៉ែធ្វើពលីកម្មអស់ជាច្រើនថ្ងៃអស់ជាច្រើនខែអស់ជាច្រើនឆ្នាំ ក្នុងការពផ្ទៃគឺរូបកូន។ម៉ែ!ម៉ែធ្វើពលីកម្ម មួយទៀតគឺពេលប្រសូតកូន ម៉ែ!ពេលម៉ែប្រសូតកូន នេះឯងគឺជាពលីកម្មដ៏លំបាកដ៏សែនធ្ងន់ធ្ងរមួយសម្រាប់ម៉ែ ម៉ែ! ម៉ែស្រែកម៉ែយំម៉ែហត់នឿយ ប៉ុន្តែទោះបីការហត់នឿយ មានសម្រាប់ម៉ែយ៉ាងណាក៏

ដោយ ក៏ម៉ែ!ម៉ែបានតាំងចិត្តទុកជាស្រេចហើយ ថាខ្ញុំធ្វើពលិកម្មបែបនេះ គឺខ្ញុំពលិកម្មដើម្បីកូនខ្ញុំ ឱ្យកូនខ្ញុំបានឃើញពន្លឺថ្ងៃនឹងគេ។

ម៉ែ!ម៉ែឆ្លងផុតគ្រោះថ្នាក់បាន ចំពោះការប្រសូតកូនមក ប៉ុន្តែមានអ្នកម្តាយខ្លះ ខំចំណាយពេលវេលាផង ចំណាយមាសប្រាក់ផង ចំណាយកំលាំងកាយចិត្តផង តែនៅជួយកូនប្រុសស្រីនោះមិនបាន អ្នកម្តាយនោះត្រូវបាត់បង់ជីវិតបាត់បង់សតិស្មារតី ក្លាយទៅជាមនុស្សវិកលចរិតព្រោះគាត់មិនបានការ គាត់គ្មានលទ្ធភាព គាត់មិនអាចធ្វើពលិកម្មជួយកូនស្រីប្រុសបានកូនប្រុសស្រីនោះត្រូវរស់នៅដោយខ្វះភាពកក់ក្តៅ។ម៉ែ!ចំពោះម៉ែរបស់កូនវិញ ម៉ែក្លាហាន

ណាស់ ព្រោះម៉ែអាចជួយកូនបាន ម៉ែ!ម៉ែមាន សមត្ថភាពទាំងលទ្ធភាព ព្រោះម៉ែបានធ្វើពលីកម្មក្នុងការឧបត្ថម្ភដល់កូន ឱ្យបានស្គាល់ភាពសប្បាយ កូនមិនដែលជួបប្រទះបញ្ហាតែបើមានបញ្ហាវិញ ម៉ែ! ម៉ែទទួលរងតែឯងម៉ែឱបក្រសោបតែឯង ម៉ែ!ម៉ែយកបញ្ហាទាំងអស់នោះ ធ្វើជាគ្រឿងអលង្ការរបស់ម៉ែ ម៉ែ!ម៉ែពលីកម្ម ហើយម៉ែចាប់យកបញ្ហាទាំងអស់នោះមកប្រដាប់កាយចិត្តរបស់ម៉ែ ។

ម៉ែ!ម៉ែរបស់កូនឆ្លាតណាស់ ម៉ែគិតហើយទើបម៉ែធ្វើពលិកម្ម នូវអ្វីដែលម៉ែខំស្ថាបនាឡើងមក ពេលនេះគឺម៉ែខំស្ថាបនាពលិកម្មដើម្បីកូនតែមួយប៉ុណ្ណោះ បើគ្មានរូបកូនក៏អ្នក

ម៉ែមិនខំដើម្បីធ្វើអ្វីដែរ តែនេះម៉ែ!ម៉ែខំធ្វើពលីកម្មដើម្បីកូន ម៉ែពុះពាររាល់ឧបសគ្គ ការលំបាកយ៉ាកយ៉ាប់ដែលមិនអាចទ្រាំបាន តែម៉ែរបស់កូនអាចកែអាចរៀបចំបានទាំងអស់ ការបំពេញនូវរាល់ការងារគ្រប់យ៉ាង បានសម្រេចគឺដោយសារតែរូបកូន។

## ១៧~ម៉ែធ្វើពលីកម្មដើម្បីកូន ជាកំណាព្យ

✍..📖

កូនអើយដឹងទេ ពលីកម្មម៉ែ

ដើម្បីថ្ងើមថ្ងៃ លះបង់គ្រប់យ៉ាង

អស់ទាំងហឫទ័យ ដល់កូនប្រុសស្រី

ជាឈាមជ័រម៉ែ។

ពលីអ្នកម្ដាយ អស់ច្រើនខែឆ្នាំ
មិនមានទំនេរ គ្មានទាំងចន្លោះ
ឥតបីកែប្រែ លំបាកច្រើនទ្វេ
នៅក្នុងលោកា។

ម៉ែខំម៉ែក្រែង អ្នកម្ដាយរអែង
ទោះបីសោកា ទោះម៉ែហត់ក្រៃ
ដួងចិត្តឈឺផ្សា អ្នកម្ដាយសោភា
ពលីជានិច្ច។

អគ្រាត្រយប់ស្ងាត់ ព្រះសូរិយាបាត់
លេចទៅខាងលិច រនោចងងឹត
ភ្លៀងស្រក់តិចៗ ចិត្តលោករំលេច
ស្លាបនាកូនថ្លៃ។

លះបង់ទាំងកាយ អ្នកម៉ែចំណាយ
មិនសន្សំថៃ លះបង់ផ្លូវចិត្ត
អ្នកម្តាយខំថ្នៃ ផ្គាប់ផ្គុនពិសី
ឱ្យបានអស្ចារ្យ។

ពលីខ្ពង់ខ្ពស់ ពលីនោះហួស
កម្រិតចិន្តា មិនខ្វះលទ្ធភាព

សម្រាប់បុត្រា កូនស្រីផងណា

គ្មានការត្អូញត្អែរ។

ចិត្តម៉ែវិយោគ រូបកាយកើតរោគ

ព្រោះកូនមាសស្នេហ៍ វិប្បដិសារី

អស់ជាច្រើនខែ ដួងចិត្តអ្នកម៉ែ

នៅតែពលី។

ពលីទាំងឈាម នៅក្នុងជានាម

ព្រះកូនប្រុសស្រី ព្រះបង្កើតកូន

សែនមានអត្ថន័យ បានជាលកលៃ

ពលីដល់ពៅ។

អស់ច្រើនយ៉ាងណា ពលីមាតា

មានប៉ុណ្ណាកូវ ជីវិតចុងក្រោយ

អ្នកម៉ែត្រូវទៅ ចោលបុត្រឆោមឆ្លៅ

ព្រោះម៉ែមរណា។

# ១៨~សេចក្តីវិយោគរបស់លោកពុក

✍...📖

ពុក! តាំងពីកូននៅតូចរហូតកូនពេញរូបរាងមានរូបស្រស់បស់ គួរជាទីស្នេហារបស់លោកពុក ពុក!ស្រលាញ់ស្មោះស្ម័គ្រចំពោះរូបកូនមិនថាយប់ឬមួយថ្ងៃនោះទេ លោកពុកតែងតែនឹកឃើញនូវសំណើចបុត្រ។

ពេលយប់ស្ងាត់ ឮសូរតែសំឡេងចង្រិតស្រែកយំទ្រហឹងអឺងកង ជាមួយនិងលោកពុកដែលកំពុងយកដៃគងថ្ងាស់ គិតរកវិធីសាស្ត្របែបណា ដើម្បីជួយកូនដែលជាទីសំណព្វបេះដូងរបស់ពុក។ពុក! ពុកគិតហើយគិតទៀតស្វែង

រកផ្លូវមួយណាសម្រាប់ឱ្យកូនដើរ បើកូនដើរផ្លូវខុស ពុកពិតជាឆាបឆួលច្រាលរន្ទាលឡើងនូវភ្លើងទុក្ខ ពុក! ចិត្តរបស់ពុកបានចែកជាបំណែកញែករាប់មិនបានគណនាមិនអស់។

ពុក! សេចក្តីសុខរបស់ពុកគឺស្ថិតនៅលើកូន កាលណាបើកូនស្តាប់ហើយរស់នៅនែបនិត្យ កៀកកិតជាមួយលោកពុកគ្រប់ពេលវេលា ពុក! កូនប្រុសពុកមិនលេងល្បែងស៊ីសងមិនញៀនថ្នាំម៉ានោះ បេះដូងរបស់ពុកឥតស្រាំឡើយ ឯកូនស្រីពុកវិញមិនរត់ចេញពីផ្ទះព្រោះហេតុតែរឿងស្នេហា ពុក!នោះជាសេចក្តីសុខដែលកាត់ថ្លៃមិនបានសម្រាប់លោកពុកឬប្រៀបបីដូចជាបានឡើងឋានសួគ៌ ទាំងនៅមានជីវិត

ដូច្នោះឯង។

ពុក! បើផ្ទុយទៅវិញ កូន!កូនបែរជាមិនស្តាប់ពុក ខ្ពើមរអើមពាក្យទូន្មានរបស់លោកពុក បោះបង់ចោលលោកពុក ទុកលោកពុកប្រៀបបីដូចជាជនដទៃ ឬប្រៀបបីដូចជាសម្រាមដែលកូនដើរជាន់ទៅវិញនោះ ពុក!ពុកក្តៅណាស់ខ្លោចផ្សាណាស់ ប្រៀបដូចជាធ្លាក់នរកទាំងរស់ដូច្នោះឯង។

ពុក!សេចក្តីអាម៉ាស់របស់ពុក ព្រោះហេតុតែពុកលើកដៃសំពះអ្នកដទៃ សូមលុយគេដើម្បីកូនទាំងកណ្តាលថ្ងៃក្តៅស្ទើរតែឆេះហើយត្រូវគេគំរាមប្រមាថ មើលងាយគ្រប់បែបយ៉ាងតែពុកមិនយកមកដាក់ ក្នុងហឫទ័យរបស់ពុក

នោះទេ តែបើកូនធ្វើដូចខាងលើវិញ ពុក! ពុក
ពិតជាស្លាប់ពុំខានឡើយ។

ពុក! ពុកធ្វើជំនួញគ្រប់បែបយ៉ាងទោះ
ជំនួញនោះខាតក្តីមិនខាតក្តី ចំណេញក្តីមិន
ចំណេញក្តី ហើយត្រូវទទួលរងនូវបញ្ហាយ៉ាង
ណាក៏ដោយ តែមិនដូចជាកូនដែលធ្វើឱ្យខាតផ្លូវ
ចិត្តរបស់ពុកឡើយ ពុក!ពុក! កូនខុសហើយកូន
អាត្មានិយមណាស់ សូម្បីគុណរបស់លោកពុក
ដែលធ្ងន់ដូចប្រឹថពីល្វឹងល្វើយដូចវេហា តែកូន
មើលមិនឃើញ កូន! កូនជាមនុស្សភ្នែកងងឹត
ដែលនៅជាមួយមាសពេជ្រ ហើយមិនដឹងមិន
ស្គាល់ទៀត ពុក!ពុកឱ្យកូនសូមទោសណាំពុក
ណាំ។កូនមិនសមជាកូនរបស់ពុកនោះទេព្រោះ

កូនមិនទទួលឱវាទលោកពុក តែកូនបែរជារុញច្រានលោកពុកឱ្យលោកពុកធ្លាក់នរកទាំងស្រស់ កូន!កូនខុសហើយខុសធ្ងន់ណាស់សម្រាប់ពុក។

## ១៩~សេចក្តីវិយោគរបស់លោកពុក | ជាកំណាព្យ

✍...📖

តើកូនយល់ទេពាក្យថាវិយោគ

នោះគឺជារោគដែលកើតពីកូន

មិនស្តាប់បង្គាប់លោកពុកមាសស្ងួន

ព្រោះតែនឹមន្ទូនមិនឃើញព្រះថ្លៃ។

ពុកស្លាប់ទៅហើយតែនៅស្រណោះ

ភក្តីសែនស្មោះនោះលើសអ្វីៗ

លើសមាសលើសពេជ្រលើសកែវចរណៃ

វត្ថុដទៃប្រៀបប្រដូចគ្មាន។

កូនអើយកូនប្រុសសំណព្វហឫទ័យ

ឱ!កូនមាសស្រីស្រស់ផ្ទឹមពុំបាន

ពុកសូមអង្វរណាកែវកល្យាណ

កុំបង់បោះប្រាណចោលពុកណាកូន។

កូនប្រុសពុកអើយកុំញៀនថ្នាំណា

កុំជក់កញ្ឆានាំឱ្យខូចខ្លួន

បាត់អនាគតកូនលែងមាំមួន

ត្រូវរោគរុកគួនបាត់បង់ស្មារតី។

កូនស្រីពុកដែរណាំមាសឆោមយង់

ស្រីត្រូវព្រីទ្ធិប្រុងនៅក្នុងដួងថៃ

កុំតាមស្នេហាក្បត់ចោលពុកថ្លៃ

ឱ្យពុកក្សិណក្ស័យចោលទីបលោកា។

បើពុកស្លាប់ទៅកូនរស់បានសុខ

ពុកមិនកើតទុក្ខព្រោះកូនសុខា

វិយោគលោកពុកពិតមានខ្លឹមសារ

សូមស្រស់កន្និដ្ឋាសុខគ្រប់ជាតិអើយ។

## ២០~ពុកម៉ែបង្ហូរឈាមដើម្បីកូនប្រុសស្រី

✍...📖

ពុក!ម៉ែ! បង្ហូរឈាមបង្ហូរញើសដើម្បីកូន ការបង្ហូរឈាមរបស់ពុករបស់ម៉ែ ចេញមកគ្មាននរណាបង្ខិតបង្ខំ អ្នកម៉ែលោកពុកនោះទេ តែគឺជាទឹកចិត្តដ៏បរិសុទ្ធ របស់លោកពុកអ្នកម៉ែ ដែលមានចំពោះកូនប្រុសស្រី។

ពុក!ម៉ែ! ឈាមដែលនៅក្នុងខ្លួនរបស់កូនគឺសុទ្ធតែឈាម របស់ពុករបស់ម៉ែដែលបាន

បង្ហូរឈាមទាំងយប់ទាំងថ្ងៃឱ្យដល់កូន។

ញើសពុកញើសម៉ែក៏ដូចឈាម របស់ពុកម៉ែដែលខំបង្ហូរដើម្បីកូន តាំងពីកូនស្ថិតនៅក្នុងផ្ទៃរហូតប្រសូតិកូនធំ ការបង្ហូរឈាមរបស់ម៉ែរបស់ពុកវាច្រើនជាងមហាសមុទ្រទៀត។

ទឹកមហាសមុទ្រ រាប់លានកោដិគ្មាននរណាអាចរាប់បានយ៉ាងណា ឈាមម៉ែឈាមពុកក៏ដូចគ្នា គ្មាននរណាអាចគណនាថាប៉ុណ្ណេះប៉ុណ្ណោះបានឡើយ។ឈាមពុក!ឈាមម៉ែ! មានចំនួនមួយតក់វាច្រើនជាងមហាសមុទ្រមួយ ចុះទម្រាំបើឈាមក្នុងខ្លួនម៉ែពុកទាំងអស់ តើស្មើមហាសមុទ្រប៉ុន្មាន?

ពុក!ម៉ែ!ឈាមរបស់ពុកឈាមរបស់ម៉ែ

គឺមានន័យសម្រាប់កូនណាស់ ព្រោះឈាមរបស់ម៉ែឈាមរបស់ពុក បានបង្ហាញពីដួងចិត្តដែលមានមហិច្ឆតាមកលើរូបកូន។

ការមិនរាថយ និងការមិនចុះចាញ់ស៊ូសម្រកឈាម បង្ហូរឈាមបញ្ចេញឈាមដើម្បីកូនៗគ្រប់គ្នាដែរ។ លោហិតក្រហមមានពណ៌ឆ្អិនឆ្អៅ ដែលតាំងនៅក្នុងខ្លួនរបស់ម៉ែនិងពុករាល់ថ្ងៃនេះគឺពុកនិងម៉ែ ថែរក្សាដោយសង្ឃឹមថាថ្ងៃណាមួយ ពុក!ម៉ែ!នឹងបង្ហូរឈាមដែលម៉ែខំសន្សំទុកនោះផ្តល់ឱ្យកូនមិនខានឡើយ។

ឱ!ព្រះលោហិតដ៏បរិសុទ្ធអើយ!សូមអ្នកកុំទាន់ផ្តន្ទាទោសខ្ញុំអី ថ្វីត្បិតថាអ្នកគឺជាអ្នកមានគុណរបស់ខ្ញុំ ដែលពុកដែលម្តាយបានផ្តល់ឱ្យខ្ញុំ

សូមអ្នកកុំទាន់ស្រក់ហូរទៅណា ចាំខ្ញុំបំរើមាតាបិតារបស់ខ្ញុំសិន។ ពុក! ម៉ែ! លោហិតលោកទាំងពីរបានបញ្ជាក់ដល់កូនថា លោកទាំងពីរមានមហាគុណសម្រាប់កូនណាស់ ពុក!ម៉ែ! សូមពុកម៉ែកុំព្រួយទៀតអី ការបង្ហូរឈាមរបស់ម៉ែពុកទាំងប៉ុន្មាន កូន!កូននិងខំបីបមឱ្យបានល្អតបស្នងឱ្យបានល្អជាទីបំផុត។

ឈាមរបស់ម៉ែហើយនឹងពុក គឺជាមតីកប្រចាំជីវិតកូនហើយឈាមម៉ែឈាមពុក នៅតែក្រហមនិងដក់ជាប់ក្នុងបេះដូងរបស់កូនពុកម៉ែ! សម្រែកឈាមម៉ែនឹងឈាមពុក បានដាស់តឿនចិត្តកូនថា ត្រូវតែថែរក្សានូវកំណាប់គឺឈាមលោកជារៀងរហូតតទៅណា។

២១~ពុកម៉ែបង្អួរឈាមដើម្បីកូនប្រុសស្រី | ជាកំណាព្យ

✍…📖

ម៉ែបង្ហូរឈាមក្រោមមេឃលើដី

ស្រក់ចេញពីផ្ទៃឥតបីសោកស្ដាយ

ដើម្បីមាសឆ្អិនមានរូបមានកាយ

ស្រស់ល្អឆោមឆាយលើភពលោកីយ៍។

ពុកបង្ហូរឈាមស្រក់លើពសុធា

ក៏ព្រោះសោភាបានរស់មានន័យ

បើកភ្នែកឃើញលោកសែនល្អប្រិមប្រិយ

ពុកស៊ូតែក្បែយប្ងូជាឱ្យកូន។

តំណក់ឈាមម៉ែនៅក្បែរឈាមពុក

គឺជាឈាមសុខរបស់មាសស្ងួន

ឈាមផ្តល់ជីវិតឱ្យកូននឹមនួន

ចែកកូនផ្ទួនៗឈាមម៉ែស្ថិតជាប់។

សម្រែកឈាមព្រះលោហិតមានគុណ

ស្រែកហៅតូចតន់ជាម្ចាស់គួគាប់

ថាកូនពន្ធកកូនមិនអភ័ព្វ

សូមកូនកុំជាប់ល្បែងបំផ្លាញខ្លួន។

ឈាមស្រែកកុំញៀននូវថ្នាំកញ្ឆា

ឱ!កូនមាតាស្តាប់ពាក្យចុងជូន

ពាក្យពុកកូនដែរថាថៃឱ្យមូន

កុំបណ្តោយខ្លួនដែលគេពញ្ញាក់។

ឈាមមិនអស់ចិត្តបើកូនពាលា

បំភ្លេចគ្រប់គ្នាដោយគ្មានអួលអាក់

បង្ហូរជាតិនេះឈាមក្តៅសស្រោក់

សូនកូនកុំស្មគ្រម៉ែពុកសូមចិត្ត។

# ២២~ពេលកូននៅក្នុងពោះម៉ែ

✍📖

ម៉ែ!ចាំ/បាទ កាលកូននៅក្នុងពោះម៉ែ ម៉ែថ្នមកូនដោយមិនឱ្យទាស់ តាំងពីកូនបានមួយថ្ងៃ ម៉ែតមអាហារខ្លាចកូនម៉ែ មានបញ្ហាម៉ែខ្លាចកូនម៉ែស្លាប់ម៉ែ!ចាំ/បាទ ម៉ែមិនធ្វើការងារណាដែលធ្ងន់ ម៉ែប្រាប់ពុករបស់កូនថាខ្ញុំមិនហ៊ានធ្វើការងារធ្ងន់ៗទេ ព្រោះខ្ញុំខ្លាចប៉ះកូនរបស់ខ្ញុំ កាលកូនបានមួយថ្ងៃម៉ែថ្នមកូនប៉ុណ្ណឹង មិនឱ្យកូនទទួលទុក្ខអ្វីឡើយ។

ម៉ែ! ថាកាលកូននៅក្នុងពោះម៉ែ កូនដឹងទេ?ម៉ែមិនសប្បាយទេ ព្រោះម៉ែខ្លាច ម៉ែ

ខ្លាចកូនម៉ែមិនអាចឃើញពន្លឺថ្ងៃ ទាំងដែលកូនម៉ែមិនទាន់កើតមកផង។

ម៉ែ!ចាំ/បាទ តើម៉ែរងទន្ទឹងចាំមើលមុខកូនយ៉ាងណា? ព្រោះកូនមិនទាន់បានមួយខែផងនោះ តែម៉ែមិនខ្វល់នឹងអ្វីៗទាំងអស់ គឺម៉ែរងចាំមើលកូនរហូត។

មួយថ្ងៃផុតទៅ ពីរថ្ងៃផុតទៅបីថ្ងៃផុតទៅច្រើនថ្ងៃផុតទៅ ម៉ែមិនធ្លាប់រងចាំនរណាម្នាក់ឡើយ តែម៉ែនៅតែរង់ចាំកូនគ្រប់ពេលវេលា ម៉ែមិនហ៊ានហូបច្រើន ព្រោះម៉ែខ្លាចប៉ះទង្គិចដល់រូបកូនដែលជាទីស្រលាញ់ ស្មើដោយកែវភ្នែករបស់ម៉ែ។

ម៉ែ!ចាំ/ពេលម៉ែសម្រាកកាយ ម៉ែតែង

តែយកដៃទាំងពីរ មកអង្អែលដល់កូនពិសីដោយ យល់ថា កូនរបស់យើងធំប៉ុណ្ណាហើយម៉ែមិន នឿយណាយ ក្នុងការស្ទាបថ្នាក់ថ្នមកូននោះ ឡើយ។កូនបានពីរខែម៉ែកាន់តែត្រេកអរហួសពី ការគណនា ដេក ដើរ ឈរ អង្គុយ ម៉ែមើលទី លំនៅដែលខ្លួនធ្លាប់សម្រាក ក្រែងមានសត្វ ស្រមោចជាដើម មកយាយីបៀតបៀនដល់រូប ម៉ែហើយនឹងកូននៅក្នុងផ្ទៃរបស់ម៉ែ។

ដល់ពេលកូនគ្រប់ខែមកដល់ ម៉ែបាន សន្យាទុកមុនជាស្រេចថា ម៉ែនឹងមិនទៅណា ចោលកូនឡើយ។

ប្រាំបួនខែមកដល់ ខ្យល់កម្មមច្ចុរាជ ក៏មករង់ចាំម៉ែជាស្រេច តែម៉ែមិនព្រមចាល

ចាញ់នោះឡើយ។

តែម៉ែបែរជាត្រេកអរទៅវិញ ព្រោះម៉ែរង់ចាំថ្ងៃនេះយូរមកហើយឥឡូវនេះ វេលាមកដល់ហើយម៉ែសប្បាយចិត្តឥតឧបមាលើសពីការបាននូវរបស់អ្វីដែលសំខាន់ក្នុងលោកនោះទៀត។តែម៉ែថា កូនរបស់ខ្ញុំសំខាន់ជាង ដល់ពេលគ្រប់ខែហើយម៉ែកាន់តែសប្បាយ ព្រោះម៉ែជិតបានឃើញកូន។

ម៉ែ!ចាំ/បាទ ពេលម៉ែឆ្លងទន្លេរប្រសូតរូបកូន ម៉ែឈឺណាស់ឈឺដូចជាគេអារកម៉ែទាំងរស់ដូច្នោះ តែម៉ែទ្រាំបានម៉ែទ្រាំដើម្បីកូនតែម្នាក់ប៉ុណ្ណោះ ក្នុងមួយជីវិតរបស់ម៉ែ។

កាលណោះ កូនមិនទាន់ស្គាល់អ្វីរាក់អ្វី

ជ្រៅ ហើយអ្វីដែលថាការឈឺចាប់នោះគឺគ្មានទេ កូនមានតែការស្រែកយំ ប្រៀបបាននឹងស្តីបន្ទោសដល់រូបម៉ែថាម៉ែម្តេចម៉ែបោះបង់រូបកូនចោលយ៉ាងនេះ?ម៉ែបង្កើតរូបកូនមកនេះតើម៉ែមានអ្វីចិញ្ចឹមកូន? ម៉ែ!ចាំ/បាទ ពេលកូនប្រសូតមកភ្លាម ម៉ែសន្លប់បាត់មាត់ស្ងួនស្ងៀមលែងដឹងខ្លួនរណាហៅក៏ម៉ែមិនឮមិនដឹងអ្វីទាំងអស់ គ្រាន់តែម៉ែដឹងថាមុននេះ ម៉ែប្រសូតកូនម៉ែមកតែប៉ុណ្ណោះ ក្រៅពីនេះម៉ែមិនដឹងអ្វីទាំងអស់។

ចំណែកកូនម៉ែវិញ កូនមិនបានជួយឈឺជួសម៉ែឡើយទាំងកូនមិនដឹងថា ម៉ែរបស់កូនសន្លប់ទៀតផង ចាំបាច់និយាយថ្វី ដល់ទៅរឿងម៉ែដែលតតាំង ជាមួយនឹង សេចក្តីស្លាប់នោះ។

ម៉ែ!ចាំ/បាទ តើម៉ែចុកចាប់ឈឺផ្សាយ៉ាង ណាទៅ? មនុស្សគ្រប់គ្នាគ្រាន់តែមុតបន្លាបន្តិច ប៉ុណ្ណោះ ស្រែកថាឈឺឈឺព្រោះមុតបន្លា ចុះម៉ែ របស់កូនវិញតើម៉ែឈឺចាប់ប៉ុណ្ណា? ខ្លោចផ្សា ប៉ុណ្ណា?រីងរៃយ៉ាងណា? ម៉ែ!ម៉ែ!ចាំ/បាទ ការ សោកសង្រេងរបស់ម៉ែ កាលនោះកូនមិនបាន ដឹងទេ មែនម៉ែឈឺចាប់ណាស់ ឈឺលើសអ្វីៗ ទាំងអស់ ឈឺព្រោះប្រសូតកូន។

ម៉ែយំឱបកូននៅពេលម៉ែភ្ញាក់ឡើង ព្រោះម៉ែស្មានថាម៉ែមិនបានជួបមុខកូនទេម៉ែឱ្យ កូនបោដោះម៉ែភ្លាមឥតចាំយូរឡើយ ព្រោះម៉ែ យល់ថា កូនរបស់ម៉ែពិតជាឃ្លានបៅហើយ។

ម៉ែ!ចាំ/បាទម៉ែរបស់កូន ម៉ែជាម្លប់ដ៏

ត្រជាក់សម្រាប់រូបកូន មានម៉ែទើបកូនមានថ្ងៃនេះ សូមម៉ែរបស់កូនកុំទាន់ទៅណាចោលកូន អីណាំម៉ែណាំ! ទុកឱ្យកូនបានប្រតិបត្តិចំពោះរូបម៉ែផង ណាំម៉ែណាំ! ណាំម៉ែឧត្តមរបស់កូន។

## ២៣~ពេលកូនដឹងក្ដីឡើង

✍…📖

ម៉ែចង់និយាយប្រាប់កូនថា កាលកូននៅតូចៗម៉ែយាមម៉ែថែរក្សាកូនឥតចន្លោះឡើយ មិនឱ្យកូនមានសេចក្ដីព្រួយបារម្ភឬកូនមានសេចក្ដីទុក្ខនោះឡើយ។

ម៉ែនៅយាមកូន មិនដែលដាក់វេនជា

មួយនរណា ក្នុងការឃាមកូននោះទេ ពីមួយម៉ោងទៅមួយម៉ោង ម៉ែឃាមកូនរហូតមើលកូនមិនចេះជិនណាយ មិនចេះស្តាយពេលវេលានោះទេ។ឃាមយប់ឃាមថ្ងៃឃាមកូនគ្រប់ឥរិយាបថ៤ មិនឱ្យមានការធ្គាំធ្គងនោះឡើយ ទោះបីម៉ែឈឺក្អកចេញឈាមមក យ៉ាងណាក៏ដោយម៉ែនៅតែញញឹមរកកូនក្នុងការបមបីបុត្រថ្ងៃដដែល។

កាលកូនមិនទាន់ដឹងក្តី ម៉ែមានការបរិច្ចាគយ៉ាងច្រើនដើម្បីកូន លះបង់កំលាំងកាយចិត្តដើម្បីបញ្ចូលកំលាំងម៉ែដល់កូន។

ម៉ែ!ម៉ែ!ចាំ កាលកូននៅតូច ម៉ែនិយាយជាមួយកូនម៉ែ ដោយពាក្យសប្បុរស

ពាក្យផ្អែមល្ហែមមករកកូនកាយវាចាចិត្ត មានតែភាពទន់ភ្លន់ចំពោះកូន។

ដល់ពេលកូនធំ កូនចេញទៅរៀននៅសាលាម៉ែទិញខោអាវថ្មីៗសម្រាប់កូនទោះបីថ្លៃយ៉ាងណាក៏ដោយ ក៏ម៉ែហ៊ានចំណាយដើម្បីបុត្រដែរ នំចំណីអាហារសម្រាប់ញ៉ាំដែលមានរសជាតិឆ្ងាញ់ ម៉ែស៊ូអត់ខ្លួនឯងតែម៉ែមិនឱ្យកូនម៉ែអត់នោះទេ។ម៉ែចាំ!កូនបានរៀនម៉ែសប្បាយចិត្តណាស់ ទោះបីម៉ែមានការខ្វះខាតយ៉ាងណាក៏ដោយម៉ែនៅតែញញឹម ពេលកូនម៉ែចេញពីសាលាមកវិញ ម៉ែត្រៀមបាយម៉ែត្រៀមទឹកត្រៀមសព្វត្រៀមគ្រប់ដើម្បីកូនម៉ែ បានញ៉ាំដោយភាពរីករាយ។

កូនបានរៀនថ្នាក់ទីមួយ ម៉ែចំណាយលុយចំណាយកាក់ចំណាយប្រាក់ អស់ជាច្រើនក្នុងការទំនុកបំរុងកូន លុយបើម៉ែគ្មាន ម៉ែដើរសូមខ្ចីលុយគេដើម្បីកូនម៉ែ បានចាយនិងហូបឆ្ងាញ់និងគេ។ម៉ែចាំ/បាទ ម៉ែស្ងួកំណាញ់តែមាត់ឯង ម៉ែមិនកំណាញ់ចំពោះកូននោះទេ កូនចង់ញុាំអីកូនប្រាប់ម៉ែម៉ែទិញឱ្យកូនភ្លាម។ ក្នុងផ្ទះដ៏តូចមួយដែលប្រក់ដោយស្លឹកដូងស្លឹកត្នោតភ្លៀងធ្លាក់មកពេលណាទទឹកកូន ឱរាម៉ែមួយនេះម៉ែចុកចាប់ណាស់ ព្រោះម៉ែចិញ្ចឹមកូនជួយកូនមិនបានល្អនោះ ម៉ែយកអាវរបស់ម៉ែដណ្ដប់ឱ្យកូនដើម្បីឱ្យកូនម៉ែបាត់រងា ហើយម៉ែសួរកូនថា: កូនរងាទេកូនម៉ែ?បើកូនម៉ែឆ្លើយថារងាណាស់

ម៉ែ!ប្រញាប់ឱបកូនភ្លាម មិនឱ្យកូនទាស់ចិត្ត ទាន់នោះទេ។

ម៉ែ!លំបាកប៉ុណ្ណាក៏ឱរាម៉ែ មិនត្អូញមិនត្អែរឡើយចំពោះកូនរបស់ម៉ែក្រោយពេលមេឃរាំងភ្លៀងភ្លាមម៉ែប្រញាប់បង្កាត់ភ្លើង ដើម្បីឱ្យកូនបានផ្អើរភ្លើងឱ្យបាត់រងា។

សំលៀកបំពាក់កូន ម៉ែបោកគក់ឱ្យកូនបត់ទុកឱ្យកូនយ៉ាងរៀបរយមានរបៀប ម៉ែបង្ហាត់កូនឱ្យកូនចេះនិយាយ ពាក្យចាំ ពាក្យបាទចំពោះចាស់ទុំចាស់ព្រឹទ្ធាចារ្យ ព្រោះម៉ែមិនចង់ឱ្យកូនបាត់បង់មារយាទ ម៉ែប្រាប់ឱ្យកូនមានការឱនលំទោនដោយកាយ ម៉ែ មិនឱ្យកូនចងកំហឹងជាមួយនរណា ឈ្លោះជាមួយនរណាប្រកែក

ជាមួយនរណា មកបង្រៀនកូនតាំងពីកូនមិនទាន់ដឹងក្តីមក។

ពេលកូនរៀនដល់វិទ្យាល័យ ម៉ែកាន់តែប្រឹងប្រែងមួយកំរិតទៀត ម៉ែខំព្យាមយាមរកលុយសម្រាប់ទំនុកបំរុងកូន ព្រោះម៉ែមិនចង់ឱ្យកូនខ្វះខាតនោះទេ។ កាលកូននៅតូចកូនស្លៀកសំលៀកបំពាក់តូចៗ តែឥឡូវកូនធំសំលៀកកូនក៏ធំតាមកូនផងដែរកាលកូនរៀនថ្នាក់ទាបកូនចាយលុយតិច ឥឡូវកូនរៀនថ្នាក់ខ្ពស់ការ ចាយលុយរបស់កូនក៏ធំដែរ។

កាលកូនរៀន ថ្នាក់ទាបកូនជិះកង់ទៅរៀន ឥឡូវកូនរៀនថ្នាក់ខ្ពស់ កូនសុំម៉ែឱ្យទិញម៉ូតូឱ្យកូនម៉ែទិញឱ្យកូនបានជិះនឹងគេ។

តែម៉ែប្រាប់កូនថាចូរកូនកុំចាយតាមចិត្ត អីណាំកូនម៉ែណាំ តាំងពីកូននៅតូចឥឡូវកូនដឹងក្តី កូនចេះសរសេរដោយខ្លួនឯង មិនចាំបាច់លោកគ្រូចាប់ដៃឱ្យសរសេរទៀតឡើយ។

ម៉ែឃើញកូនម៉ែចេះ ម៉ែរីករាយឥតឧបមា ម៉ែភ្លេចអស់នូវកង្វល់ដែលមានកន្លងមកព្រោះបានកូនចេះ ម៉ែដេកក៏ញញឹមដើរក៏ញញឹម ហើយម៉ែក៏មិនភ្លេច នៅតួនាទីដែលខ្លួនម៉ែត្រូវបំពេញសម្រាប់រូបកូនតែមួយប៉ុណ្ណោះ ក្នុងជីវិតរបស់ម៉ែ ម៉ែជាធនាគារបើកប្រាក់ ម៉ែគឺជាព្រះរបស់កូន ម៉ែ!ម៉ែ! ម៉ែ! ចាំ!។

# ២៤~ពេលកូនម៉ែឈឺ

✍...📖

ម៉ែ!ពេលកូនម៉ែឈឺម៉ែស្ងោស្ងន់ ប្រញាប់ដោយសេចក្តីស្រលាញ់ នឹងសេចក្តីអាណិតអាសូរដល់កូន ម៉ែកាលនោះកូននៅតូច កូនមិនដឹង កូនគិតតែយំគិតតែពីស្រែកធ្វើឱ្យម៉ែកាន់តែចុកចាប់ខ្លាំងឡើង ហើយម៉ែឆ្ងល់ថាកូនរបស់ម៉ែកើតអី?ម៉ែសួរកូនម៉ែចងឈឺចាប់ជំនួសកូន។

ម៉ែអង្គុយមើលមុខកូន ដែលកូនឈឺហើយស្រែកយំនោះម៉ែលួងចិត្តកូន តែកូនមិនព្រមឈប់យំ ធ្វើឱ្យម៉ែយំតាមកូន។

ម៉ែមិនធ្លាប់យំ ដោយសារនរណានោះ

ទេ បើក្រៅពីរឿងរបស់ម៉ែតែពេលនេះម៉ែស្រក់ទឹកភ្នែកព្រោះឃើញកូនម៉ែឃំសំរក់ទឹកភ្នែក មិនចេះចរចារជាមួយម៉ែ ធ្វើឱ្យម៉ែកាន់តែរន្ធត់ចិត្តឥត ស្រាកស្រានបន្តិចណាឡើយ។

ម៉ែ! ស្រវាឆ្វេងស្រវាស្តាំពាក់កណ្តាលអធ្រាត្រយប់យន់ ស្ងៀមស្ងាត់បាត់ពន្លឺដួងខែឮសូរតែសំឡេងសត្វចង្រិត ស្រែកទ្រហឹងអឺងកងតែសម្រែកម៉ែឮជាងសត្វនោះទៅទៀត។

ម៉ែស្រែកហៅពុករបស់កូន ឱ្យជួយនាំផ្លូវទៅកាន់មន្ទីរពេទ្យ សូមឱ្យលោកគ្រូពេទ្យមេត្តាប្រោសប្រណីដល់កូនផងអស់ លុយប៉ុន្មានក៏ម៉ែមិនស្តាយ។

ម៉ែតក់ក្រហល់ ក្នុងចិត្តណាស់ពេល

កំពុងបីកូនដើរតាមផ្លូវ ទៅកាន់មន្ទីរពេទ្យ ព្រោះម៉ែចង់ដឹងពីជំងឺរបស់កូន ម៉ែបែកញើស ហូរញើសសស្រាក់ជោកពេញខោអាវ ដូចគេ ងូតទឹកដូច្នោះឯង។

ពុកម៉ែជូនកូនដល់មន្ទីរពេទ្យពេលណា ម៉ែប្រញាប់ដណ្ដឹងសួរលោកគ្រូពេទ្យ ពីជំងឺ របស់កូន។ ក្រោយពីលោកគ្រូពេទ្យបានបញ្ជាក់ ថា កូនម៉ែគ្មានជំងឺធំដុំដែលត្រូវកើតឡើងនោះ ម៉ែបានស្បើយពីសន្ដាន ប្រៀបបីដូចជាគេដក បន្លាចេញពីទ្រូងដូច្នេះឯង។

ម៉ែស្ទាបកូនថ្នមៗ ហើយម៉ែសួរកូន ថា កូនមិនអីទេមែនទេកូនម៉ែ? កូននៅតូចកូនមិន ចេះស្ដីបានត្រឹមតែលើកដៃលើកជើងហើយសើ

ចម៉ែក៏យល់ថាកូនរបស់ម៉ែបានធូរស្បើយហើយ។ម៉ែពុកអង្គុយសន្ទនាគ្នា ដើម្បីរកវិធីសាស្ត្រដើម្បីការពារកូនរបស់ពុកម៉ែ កុំឱ្យមានរោគាព្យាធិមកបៀតបៀនកូនទៀតអី។

ម៉ែពុកបានលះបង់គ្រប់យ៉ាងដើម្បី កូនម៉ែពុកមានម្ចាស់បំណុល ដែលសងមិនចេះរួចនោះគឺរូបកូន។

ម៉ែពុករីករាយណាស់ បើកូនម៉ែមិនឈឺពេលចូលដំណេកម៉ែបន់ស្រន់ សូមវត្ថុស័ក្តិសិទ្ធិក្នុងលោកឱ្យជួយការពារកុំឱ្យកូនឈឺទៀតអី។

# ២៥~ម៉ែជាជម្រកកូន

✍...📖

ម៉ែ! កាលកូននៅក្នុងពោះម៉ែ ម៉ែថ្នមកូនម៉ែយកពោះម៉ែ បាំងបិទដោយសំលៀកបំពាក់ក្នុងការថែរក្សាកូន ក្នុងនាមជាជម្រករបស់កូន ជាខ្ទមជីវិតរបស់កូន។ម៉ែ! កាលកូននៅតូចកូនក្ដៅម៉ែ ស្រោចទឹកឱ្យកូន ម៉ែដូសសាប៊ូឱ្យកូន ហើយជូតខ្លួនឱ្យកូនម៉ែ យកកូនដាក់លើកកម្រាល ម៉ែយកដៃទាំងពីធ្វើជាអង្រឹងអមដោយទ្រូងម៉ែផងដែរ។

ម៉ែ!កាលកូនកើតមកហើយតែកូននៅតូចម៉ែមានការលំបាកយ៉ាកយ៉ាប់គ្មានអ្នកត្រាប់

ដូចម៉ែឡើយ។

ជីវិតសាច់ឈាមរបស់កូន គឺជាសាច់ឈាមរបស់ពុកម៉ែទាំងអស់ ម៉ែពុក! ម៉ែពុកចិត្តល្អសម្រាប់កូនណាស់ បែរជាបង្វែរសាច់ឈាមទាំងអស់ក្នុងខ្លួនពុកម៉ែ ឱ្យក្លាយជាកម្មសិទ្ធរបស់កូនទៅវិញ។ បែរជាស៊ូទទួលការឈឺចាប់ជំនួសកូនគ្រប់បែបយ៉ាងដើម្បីកូន ម៉ែពុកយកជីវិតធ្វើជាទាសកររបស់កូន ធ្វើជាខ្ញុំបំរើដល់កូន កូនប្រើឱ្យពុកម៉ែធ្វើអ្វីក៏ពុកម៉ែ ស៊ូធ្វើគ្រាប់តាមកូនទាំងអស់។ពុកម៉ែ!ស៊ូធ្វើជាខ្ញុំបំរើរបស់កូនដោយឥតគិតថ្ងៃពីមួយថ្ងៃទៅមួយថ្ងៃពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំកន្លងផុតទៅយ៉ាងឆាប់រហ័ស តែម៉ែពុកមិន បានគិតថ្ងៃឡើយ។

ពុកម៉ែ! ទោះការធ្វើកិច្ចការងារហត់នឿយយ៉ាងណា ក្នុងនាមជាអ្នកបំរើកូនជាទាសកររបស់កូន ពុកម៉ែនៅតែញញឹមរកកូនដោយភាពរីករាយ នឹងដោយការស្នេហ៍គ្រស្នោះចំពោះកូន។

កូនបានធំបន្តិច ពុកម៉ែកាន់តែធ្វើជម្រកកូនឱ្យកាន់តែធំ បង្ហាញផ្លូវចិត្តលាតត្រដាងឱ្យគេឯង។

ឃើញថាពុកម៉ែ គឺជាម្លប់របស់កូនគ្រប់ពេលវេលា។តាំងពីព្រលឹមទាល់ព្រលប់ពុកម៉ែ នៅតែប្រកបកិច្ចការងារគ្មានពេលសម្រាកព្រោះពុកម៉ែ មានកាតព្វកិច្ចធ្វើជាជម្រករបស់កូនជាទាសកររបស់កូន។ ពុកម៉ែ! កាលកូនមាន

បញ្ហាកើតឡើងទោះបីបញ្ហានោះដោយមិនអាចគណនាបានយ៉ាងណាក៏ដោយ ក៏ពុកម៉ែត្រៀមខ្លួនជាស្រេច ក្នុងការជួយដោះស្រាយកូនទោះត្រូវបង់ប្រាក់អស់ច្រើនប៉ុណ្ណា នូវតែពុកម៉ែជួយកូនបានទាំងអស់ សូម្បីតែការត្អូញត្អែរបន្តិចក៏គ្មានសោះឡើយ។

សេចក្តីទុក្ខរបស់កូន គឺជាសេចក្តីទុក្ខរបស់ម៉ែពុក បើកូនម៉ែពុកជានោះគឺជាសេចក្តីសុខរបស់ម៉ែឪ បើកូនម៉ែពុកមានទ្រព្យពុកម៉ែថ្មុំថ្មើនមួយកំរឹតទៀត តែបើកូនម៉ែពុកក្រីក្រទ្រព្យសម្បត្តិវិញនោះ ពុកម៉ែឈឺចុកចាប់គឺពុកម៉ែចង់ក្រជួសកូន។ពុកម៉ែ!ស៊ូយកខ្លួនឯងធ្វើជាជណ្តើរសម្រាប់ឱ្យកូនឡើង ទោះបីជើងកូនប្រឡាក់

ដោយវត្ថុមិនស្អាត ពុកម៉ែ!ស៊ូធ្វើជាខ្ញុំបំរើរបស់កូនដោយឥតគិតថ្លៃ ពីមួយថ្ងៃទៅមួយថ្ងៃពីមួយខែទៅមួយខែ ពីមួយឆ្នាំទៅមួយឆ្នាំកន្លងផុតទៅយ៉ាងឆាប់រហ័សតែម៉ែពុកមិនបានគិតថ្លៃឡើយ។

ពុកម៉ែ! ទោះការធ្វើកិច្ចការងារហត់នឿយយ៉ាងណា ក្នុងនាមជាអ្នកបំរើកូនជាទាសកររបស់កូន ពុកម៉ែនៅតែញញឹមរកកូនដោយភាពរីករាយ នឹងដោយការស្នេហ៍គ្រស្មោះចំពោះកូន។

**បរិយាយព្រះគុណ បង្ហាញទម្ងន់**

**ដែលធ្ងន់ឥតបី ដូច្នេះគួរកូន**

ទាំងប្រុសទាំងស្រី គិតហើយកែថ្ងៃ

ពីទោសទៅគុណ។

បើកភ្នែកសំឡឹង ហើយគប្បីប្រឹង

សំឡឹងឱ្យធ្ងន់ សំឡឹងឱ្យជ្រៅ

មិនគួររិះគន់ ប្រសើរពេកពន់

ក្នុងជីវិតរ៉ា។

នាមជាមនុស្ស មិនគួរប្រទូស្ត

មាតាបិតា លោកជាផ្លូវសួគ៌

ជាផ្ទះសុខា បានផលមហា

## អមគផងដែរ។

បើស្នេហ៍ពុកម៉ែនោះពិតជាត្រូវ ឆ្លងផុតរណ្ដៅនៃក្ដីឈឺផ្សា

មានកាយនិងចិត្តជាកតញ្ញូតា ព្រមទាំងវាចារួមផងដែរ។

## បើបានកុំភ្លេចរូបម៉ែ

ម៉ែបានអ្វីហូបម៉ែឥតភ្លេចទេ

នឹកឃើញមាសស្នេហ៍គ្រប់ពេលវេលា

ស៊ូលេបទឹកមាត់តែឯងគ្រាំគ្រា

ឱ្យតែពុំងាបានញ៉ាំរីករាយ។

ដើរមួយជំហ៊ានម៉ែនឹកដល់កូន

ដូចទឹកនិងក្បូនមិនដែលនិងណាយ

ម៉ែនឹករលឹកពិសីឆោមឆាយ

ពេលទឹកពេលបាយតែងតែអាល័យ។

កូនអើយបើបានកុំភ្លេចរូបម៉ែ
គួរកូនមាសស្នេហ៍មានចិត្តប្រណី
លើកជូនរូបម៉ែទាន់ចេះធី
គិតឱ្យប្រពៃណាថ្ងៃកល្យាណ។
បើកូនដឹងគុណម៉ែសែនអរណាស់
ចិត្តម៉ែលែងស្ពះហើយណាត្រើយត្រាណ
ព្រោះម៉ែបានកូនដែលខ្លួនចង់បាន
ម៉ែបានសុខសាន្តនៅក្នុងចិន្តា។
បើផ្ទុយទៅវិញកូនម៉ែមិនដឹង
បិទភ្នែកយ៉ាងឈឹងដូចខ្វាក់នេត្រា
ម៉ែនៅក្នុងផ្ទះមិនថ្វាយទេណា
ក្រៅពីមាតាអស់អីមិនគិត។
ធ្វើជាមួយម៉ែកូនសែនស្ដាយក្រៃ
ធ្វើតែមួយថ្ងៃកូនស្ដាយពេកពិត

ស្ទើរសុំមកវិញគ្មានក្តីអាណិត

ទ្រូងម៉ែត្រូវស្ងិតស្ទើរតែមរណា។

កូនសម្លាញ់ម្តាយម៉ែឥតថាអ្វី

នៅតែបេតីនិងមាសស្នេហា

ម៉ែមិនក្រឡះនិងបុត្រសង្សារ

ឱ!កូនជីវ៉ាម៉ែឥតខឹងឡើយ។

**ចប់**



# ឈ្មោះអ្នកចូលប្រាក់

ឧបាសិកា សុខា ..........................................................................៨០០០០៛
ឧបាសិកា ត្រួច សាត .....................................................................១០០០០៛
វ៉ែន ស៊ីសុផេន និង ភរិយា ..............................................................១០០០០៛
អ្នកគ្រូ ស៊ុយវ៉ាសនា និង អ្នកគ្រូ អីវម៉ារ៉ា .............................................១០០០០៛
មាន ធំ ..................................................................................១០០០០៛
ជូប៉ាច លីឡាយ .........................................................................១០០០០៛
ញ៉ែម មាន(ស៊ូ) ........................................................................១០០០០៛
ហ៊ុយចាន់ឈូងលីសួរ ...................................................................១០០០០៛
ឧបាសក ឆាន់ទី និង ឧបាសិកា គឹមជី ព្រមទាំងបុត្រ .................................១០០០០៛
លោក អ៊ូ ស៊ីនឿន និងអ្នកស្រី ហែមចាន្នី ............................................១០០០០៛
នាង ផាន់ចាន់ថា .......................................................................១០០០០៛
កញ្ញា កន្និដ្ឋា ..........................................................................១០ ដុល្លា
កញ្ញា ស្រីពៅ ..........................................................................៥ ដុល្លា
កញ្ញា ភួន វដ្ឋា នឹង ក្រុមគ្រួសារ......................................................១០ ដុល្លា
កញ្ញា ភួន រក្សា និង មាតាក្រុមគ្រួសារ..................................................៥០០០០៛
កញ្ញា លីដា ............................................................................៥ ដុល្លា
ឧបាសក គឹម នៅ និង ឧបាសិកា ឡាយ ហ៊ុនគី .......................................១០០០០ រៀល
លោក ត្រឹង បញ្ញារុណ និង ភរិយា ឃុន ចាន់ផា ......................................១០០០០ រៀល
លោក ម្ចាស់ មុនីរក្ខិតោ ភួង រស្មី .....................................................១០០០០ រៀល
សាមណេរ រុន ........................................................................១០០០០ រៀល
ភិក្ខុ ភឿន ភួត ........................................................................២០០០០ រៀល
ឧបាសិកា ប៉ុក.........................................................................១៥០០០ រៀល
ក្អួន ដេត .............................................................................១០០០០ រៀល
ឧបាសិកា មុយ ប៊ុន...................................................................១០០០០ រៀល
កញ្ញា ដាណែត........................................................................១០០០០ រៀល
កញ្ញា ស្រីភ័ក្រ........................................................................១០០០០ រៀល

កញ្ញា សី សោភា ........................................................................១០០០០ រៀល
ឧបាសក ជា និង ភរិយា...................................................................១០០០០ រៀល
ឧបាសិកា ហួង និង បុត្រ.................................................................១០០០០ រៀល
កញ្ញា ចរិយា ..............................................................................១០០០០ រៀល
ថ ប៊ុនរុន និង ទីតូ.........................................................................១០០០០ រៀល
លោក ឈិង និង កួយរ៉ាឌី ...............................................................១០០០០ រៀល
ខែកសុខូមទេពសៅរ៉ុត ...................................................................១០០០០ រៀល
ស្មៀន ច័ន្ទជា និង យាយធីន............................................................១០០០០ រៀល
ឧបាសិកា (គ្មានឈ្មោះ)....................................................................១០០០០ រៀល
សូនជា និង តាតលី .......................................................................១០០០០ រៀល
ឧបាសិកា វណ្ណា និងនកូន១ .............................................................១០០០០ រៀល
ឧបាសិកា ...................................................................................១០០០០ រៀល
សូនជា និង តាតលី .......................................................................១០០០០ រៀល
ឧបាសិកា វណ្ណា និង កូន១ .............................................................១០០០០ រៀល
ឧបាសិកា គន់ ហៀង ព្រមទាំងបុត្រ.....................................................១០០០០ រៀល
ឧបាសិកា ភួងគិមហេង ព្រមទាំងបុត្រ..................................................១០០០០ រៀល
លោក អារ៉ា និង ភរិយា (USA) .......................................................៥០០០០ រៀល
លោក រតនា និង ភរិយា ................................................................១០០០០ រៀល
ស៊ិត នាងសុផៃ ព្រមទាំងបុត្រ ..........................................................១០០០០ រៀល
ទីសាន់ និង ភរិយា .......................................................................១០០០០ រៀល
លោកលឹម និង នាងម៉ានិន្ទ ព្រមទាំងបុត្រ..............................................១០០០០ រៀល
ទូចប៉ុង និង ផាននារី ព្រមទាំងបុត្រ.....................................................១០០០០ រៀល
ឧបាសិកា ឡៅ ទៀង ......................................................................១០០០០ រៀល
ឧបាសក ប៉ាតឡិ ឧបាសិកា ភិវ ភីន .....................................................១០០០០ រៀល
លោក តា សេងហួត និង លោក យាយទិ និង បុត្រ...................................១០០០០ រៀល
តាំងសុខ លីនឈា .........................................................................១០០០០ រៀល
លោសុខ ឡេង និងអ្នកគ្រូ ទេពណាត .................................................១០០០០ រៀល
កញ្ញា សោភា ...............................................................................១០០០០ រៀល

ក្អួយ ឆាយ នាងជឿន ........................................១០០០០ រៀល

ថាប់ រ៉ាយ ........................................១០០០០ រៀល

ឧបាសក ធិម ........................................១០០០០ រៀល

ឧបាសិកា នង ណារី ........................................១០០០០ រៀល

ឧបាសក ទុយ យ៉ូង និង ឧបាសិកា ស៊ុប សារី ........................................១០០០០ រៀល

អ្នកស្រី ឈិន អ៊ុឡាន ........................................១៤០០០ រៀល

កញ្ញា ឈឹម វល័ក្ខ ........................................១០០០០ រៀល

ប៉ាល់ហាន និង ណារី ........................................១០០០០ រៀល

ឡេង វណ្ណា ........................................១០០០០ រៀល

លីគុងឃៀង ........................................១០០០០ រៀល

សៅចាន់ហម ........................................១០០០០ រៀល

លឹម សេលី និងភរិយា ........................................១០០០០ រៀល

ឧបាសិកា យក់គុណ ........................................១០០០០ រៀល

លឹម ឡាប ........................................១០០០០ រៀល

ក្អួយ ងុយ ........................................៦០០០ រៀល

លីម ឆាយ និង ភរិយា ព្រមទាំងបុត្រ ........................................៦០០០ រៀល

អោម ប៊ុន ហ៊ួន និង ចាន់នី ........................................៦០០០៛

លន់ សុផល ........................................៦០០០ រៀល

លន់ សំណាម និង លន់ ស៊ីរ៉ូន ........................................៦០០០ រៀល

ខាំ លន់ និង ភូ ផល្លា ........................................៦០០០ រៀល

យាយរឿន និង ភរិយា ព្រមទាំងបុត្រ........................................៦០០០ រៀល

ប៊ុនសៅរ័ត្ន ........................................៦០០០ រៀល

សឹម លាងស្រេង គឹម យេង ........................................៦០០០ រៀល

ម៉ាត់ សារ៉ន ........................................៦០០០ រៀល

តា វេង យាយម៉ៅ ........................................៦០០០ រៀល

ចាន់ ប៊ុនលី ........................................៦០០០ រៀល

ខូវ គន្ធា និង ស្វាមី ព្រមទាំងបុត្រ........................................៦០០០ រៀល

ខូវ ខាគីម និង ស្វាមី ព្រមទាមងបុត្រ........................................................................៦០០០ រៀល
ជច លីន ថៃ នាង ហួរភួន ........................................................................៦០០០ រៀល
ឆេនឈួត និងភរិយា ព្រមទាំបុត្រ ........................................................................៦០០០ រៀល
វ៉ាន និង ខា ........................................................................៥០០០ រៀល
ម៉ា ម៉ាន ម៉ា យ៉ម ........................................................................៥០០០៛
ឧបាសិកា ណាត ជឿន ទេព វ៉ាន........................................................................៥០០០៛
ស៊ាង ផាន ........................................................................៥០០០៛
ម៉ែន សុខា ........................................................................៥០០០៛
កែវ ចំរើន ........................................................................៥០០០៛
ថា និង លាភ ........................................................................៥០០០៛
ឧបាសក ធូនអ៊ួន ឧបាសិកា ប៉ែន ស៊ីម ........................................................................៥០០០៛
ឧបាសិកា តាំង គាវ ........................................................................៥០០០៛
ឧបាសក ចុង សឿ ........................................................................៥០០០៛
មាស សារ៉ៃន ........................................................................៥០០០៛
នាង ដើង ........................................................................៥០០០៛
ឧបាសិកា ហ៊ន ........................................................................៥០០០៛
សយ និងជី ........................................................................៥០០០ រៀល
អ្នកស្រី វុត....... ........................................................................៥០០០ រៀល
ឧបាសិកា វ៉ុង ........................................................................៥០០០ រៀល
កញ្ញា សុធារី ........................................................................៥០០០ រៀល
ឧបាសិកា អោគិមអេ ........................................................................៥០០០ រៀល
ឧបាសិកា ភុំអួន ........................................................................៥០០០ រៀល
ឧបាសិកា តាន់ គីម សុង........................................................................៥០០០ រៀល
ឧបាសិកា ឡាំអ៊ិតនា និង បុត្រ ........................................................................៥០០០ រៀល
សេង លាប ........................................................................៥០០០ រៀល
ឧបាសិកា ហេ ........................................................................៥០០០ រៀល
ឧបាសិកា អួន ........................................................................៥០០០៛

ឧបាសិកា ណាំ ..........................................................................៥០០០៛
ឧបាសក ធូនសាអ៊ួន ឧបាសិកា ប៉ែនស៊ីម ....................................................៥០០០៛
ឧបាសក អឿង ឧបាសិកា សួរ ...............................................................៥០០០៛
សំចន្ថា.......................................................................................៥០០០៛
ស៊ុនស្រីមុំ ..................................................................................៥០០០៛
ឧបាសក ហេងវ៉ា និង ភរិយា ...............................................................៥០០០៛
ឈួន វណ្ណមាលី .............................................................................៥០០០៛
ឧបាសក មុន និង ឧបាសិកា យ៉ម ...........................................................៥០០០ រៀល
ស្រី ទូច .....................................................................................៥០០០ រៀល
បង សឿក ...................................................................................៥០០០ រៀល
សឿន ច្រឹម ..................................................................................៥០០០ រៀល
តា ឈូក យាយ យីត .........................................................................៥០០០ រៀល
លោកយាយ ប៊ិនធីន ..........................................................................៥០០០ រៀល
ចន្ថា យា .....................................................................................៥០០០ រៀល
ញោម ម៉ៅ ....................................................................................៥០០០ រៀល
កួយ រឿន .....................................................................................៥០០០ រៀល
គាំ សរ .......................................................................................៥០០០ រៀល
លោក យាយ តែប .............................................................................៥០០០ រៀល
វៃ នាងផង ...................................................................................៥០០០ រៀល
យាយ កា .....................................................................................៥០០០ រៀល
ចៃ អួយ និង ស្វាមី ..........................................................................៥០០០ រៀល
ម៉ែស្រីម៉ុច ....................................................................................៥០០០ រៀល
ម៉ា រុំ .........................................................................................៥០០០ រៀល
ប៊ី សុខន .....................................................................................៥០០០ រៀល
យួន ឡុន់......................................................................................៥០០០ រៀល
ធី និង ភរិយា ព្រមទាំងបុត្រ ..................................................................៥០០០ រៀល
គួន ណៃ .....................................................................................៥០០០ រៀល

សុនេយ្យៈមេពិសី ....................................................................៥០០០ រៀល
មេ ទាង ..............................................................................៥០០០ រៀល
